# ជំពូកទី ៩

## ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់គំរោង

Draft

# ជំពូកទី ៩

## ផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងតំបន់គំរោង

### ៩.១ សេចក្តីផ្តើម

នៅក្នុងជំពូកនេះគឺ រៀបរាប់អំពីផែនការគ្រប់គ្រងបរិស្ថាន (ផ.គ.ប)ដែលនឹងត្រូវអនុវត្តនីតាមដំណាក់កាលរបស់គំរោង ជាពិសេសក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិថែទាំគំរោង និងបញ្ចប់គំរោង ។ គោលបំណងសំខាន់នៃ ផ.គ.ប នេះគឺត្រួតពិនិត្យ តាមដាននូវ ការអនុវត្តវិធានការណ៏កាត់បន្ថយហេតុប៉ះពាល់បរិស្ថានដែលបានចែងក្នុងជំពូកទី [redacted] ។

ការអនុវត្តផ.គ.ប នេះជាភារកិច្ចរបស់ក្រុមចំរុះ, ដែលមានការចូលរួមពីការិយាល័យ , មន្ទីរ , ក្រសួងដែលពាក់ព័ន្ធដែលនឹងត្រូវបង្កើតឡើងដោយម្ចាស់គំរោងរួមជាមួយក្រសួងបរិស្ថាន ។ ក្រុមត្រួតពិនិត្យ និងការឃ្លាំមើលវិធានការណ៏ការពារបរិស្ថាននេះ និងក្រោមការត្រួតពិនិត្យ និងតាមដានពីក្រសួងបរិស្ថាន ។

### ៩.២ សមាសភាពនៃក្រុមត្រួតពិនិត្យ និងការឃ្លាំមើលវិធានការការពារបរិស្ថាន

សមាសភាពក្រុមការងារត្រួតពិនិត្យ និងឃ្លាំមើលលើគំរោងវារីអគ្គិសនីកំចាយនេះមានដូចតទៅ :

**ក. ក្រុមការងារថ្នាក់កណ្តាលឬការអន្តរក្រសួង**

១- ក្រសួងបរិស្ថាន រួមមាន មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន, មន្ត្រីជំនាញតំណាងឱ្យនាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន, និងនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួង

២- មន្ត្រីជំនាញតំណាងឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៣- មន្ត្រីជំនាញតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៤- មន្ត្រីជំនាញតំណាងឱ្យក្រសួងធនធានទឹក និងឧតុនិយម

៥- មន្ត្រីជំនាញតំណាងឱ្យក្រសួងរៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី

៦- មន្ត្រីជំនាញតំណាងឱ្យក្រសួងទេសចរណ៏

៧- មន្ត្រីជំនាញតំណាងឱ្យក្រសួងសាធារណការ និង ដឹកជញ្ជូន

៨- មន្ត្រីជំនាញតំណាងឱ្យក្រសួងកសិកម្ម

៩- មន្ត្រីជំនាញតំណាងឱ្យរដ្ឋបាលព្រៃឈើ

១០- មន្ត្រីជំនាញតំណាងឱ្យរដ្ឋបាលជលផល

១១- អ្នកតំណាងឱ្យក្រុមហ៊ុន ។

**ខ. ក្រុមការងារអនុថ្នាក់កណ្តាលឬការខេត្ត**

១- មន្ត្រីជំនាញតំណាងឱ្យមន្ទីរបរិស្ថាន ខេត្តពាក់ព័ន្ធ

២- មន្ត្រីជំនាញតំណាងឱ្យមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តពាក់ពន្ធ័

៣- មន្ត្រីជំនាញតំណាងឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តពាក់ព័ន្ធ

៤- មន្ត្រីជំនាញតំណាងឱ្យមន្ទីរធនធានទឹក និងឧតុនិយម ខេត្តពាក់ព័ន្ធ

Draft

៥- មន្ត្រីជំនាញតំណាងឱ្យមន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តពាក់ព័ន្ធ

៦- មន្ត្រីជំនាញតំណាងឱ្យមន្ទីរទេសចរណ៍ ខេត្តពាក់ព័ន្ធ

៧- មន្ត្រីជំនាញតំណាងឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពាក់ព័ន្ធ

៨- មន្ត្រីជំនាញតំណាងឱ្យខណ្ឌរដ្ឋបាលព្រៃឈើ ខេត្តពាក់ព័ន្ធ

៩- មន្ត្រីជំនាញតំណាងឱ្យខណ្ឌរដ្ឋបាលជលផល ខេត្តពាក់ព័ន្ធ

១០- មន្ត្រីជំនាញតំណាងឱ្យមន្ទីរសាធារណការ ខេត្តពាក់ព័ន្ធ

១១- អាជ្ញាធរដែនដី ខេត្តពាក់ព័ន្ធ (ភូមិ ឃុំ/សង្កាត់ ស្រុក ក្រុង ខេត្ត)

១២- អ្នកតំណាងឱ្យក្រុមហ៊ុន ។

សមាសភាពក្រុមខាងលើមានតួនាទីពិនិត្យតាមដានដោយផ្ទាល់ និងដោយប្រយោល ដើម្បីជួយតំរែតំរង់ និងកែលំអរាល់ការខ្វះខាតរបស់ក្រុមហ៊ុនក្នុងការអនុវត្តវិធានការណ៍ការពារបរិស្ថាន របស់គំរោង ។

**<u>បញ្ជាក់:</u>** សមាសភាពមន្ត្រីទាំងអស់នេះ នឹងត្រូវផ្លាស់ប្តូរតួនាទី និងមុខងារក្រោមការចង្អុលបង្ហាញពីក្រសួងបរិស្ថាន ។

## ៩.៣ វិធានការណ៍សំខាន់ៗសំរាប់ការពារបរិស្ថាន

យោងតាមអនុក្រឹត្យស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងយោងតាមលទ្ធផលនៃការសិក្សា ស្តីពី ការវាយតំលៃហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គម ដែលបង្កឡើងដោយសារសកម្មភាពនៅគ្រប់ដំណាក់កាលរបស់គំរោង ដូចបានរៀបរាប់នៅក្នុងជំពូកទី៧ និងជំពូកទី៨ដែលម្ចាស់គំរោងនឹងរៀបចំកំណត់នូវវិធានការសំខាន់ៗមួយចំនួនសំរាប់ធ្វើការទប់ស្កាត់ និងកាត់បន្ថយនូវរាល់ហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន ដើម្បីធានាបានការគ្រប់គ្រងធនធានបរិស្ថានតំបន់នោះ ដោយប្រសិទ្ធិភាពស្របទៅតាមលក្ខណៈបច្ចេកទេស និងបទដ្ឋានបរិស្ថានព្រមទាំងធានាឱ្យគំរោងអភិវឌ្ឍន៍ប្រកបដោយស្ថេរភាព ដែលក្នុងនោះរួមមាន (ចំណុចសំខាន់ៗដែលត្រូវសរសេររបាយការណ៍ជូនក្រសួងបរិស្ថាន):

- ការរៀបចំផ្នែក ឬ ក្រុមទទួលខុសត្រូវសំរាប់ការអនុវត្តផែនការការងារ ។
- ការកំណត់ពេលវេលាធ្វើការងារឱ្យច្បាស់លាស់ ក្នុងកិច្ចការការពារបរិស្ថាន ។
- ការបំពាក់ឧបករណ៍ការពារសុខភាព គ្រោះថ្នាក់ និងគ្រឿងចក្រទំនើបៗតាមបែបផែនបច្ចេកទេស ។
- កិច្ចការពារ និងបង្ការជំងឺរាតត្បាតផ្សេងៗ ។
- ការគ្រប់គ្រងសំណល់រឹង រាវ និងសំណល់សារធាតុពុល ។
- ការធ្វើកន្លែងទុកសំណល់រឹង ។
- ការការពារការហូរច្រោះនៅកន្លែងកាយជញ្ជាំងភ្នំ និងកន្លែងចាក់សំណល់ដី និង ថ្មដោយដាំស្មៅ និងដើមឈើការពារ ។
- ការកាត់បន្ថយភាពល្អក់នៅកន្លែងលាងថ្ម និងកន្លែងរោងចក្រលាយបេតុង ។
- កិច្ចការជំរុញឱ្យមានការដាំដើមឈើ នៅទីសាធារណៈ ឬតំបន់ជុំវិញតំបន់ការពារទាំងនោះ ។
- ការធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជំនាញក្នុងការត្រួតពិនិត្យមើលទីតាំងបច្ចេកទេសនិងទទួលយកនូវការកែ ប្រែបច្ចេកទេសណាមួយដែលជំនាញតម្រូវឱ្យធ្វើ ។
- ការធ្វើការអភិរក្ស ប្រភេទសត្វព្រៃសំខាន់ៗដែលធ្លាប់មាននៅតំបន់គំរោង និងដំណើការស្ថានីយ៍ចិញ្ចឹមត្រី ។
- ការធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំអំពីប្រភេទព្រៃឈើ និងពពួកសត្វព្រៃ ដែលត្រូវអភិរក្សក្នុងតំបន់គំរោង ។

Draft

- ការធ្វើការផ្សព្វផ្សាយ និង អប់រំណែនាំ វិធីសាស្ត្រការពារសុខភាព អនាម័យ-សុវត្ថិភាពការងារ ។
- ការត្រៀមថវិកាបំរុងទុកសំរាប់ប្រតិបត្តិផែនការគ្រប់គ្រងបរិស្ថាន និង ការចំណាយលើថវិកានេះ ។

**បញ្ជាក់:** ក្រុមហ៊ុននឹងត្រៀមថវិការចំនួន USD ១៧.៥០០.០០០ (មួយម៉ឺន ប្រាំពីរពាន់ ប្រាំរយពាន់ដុល្លាអាមេរិក) សំរាប់កិច្ចការពារបរិស្ថាន ក្នុងនោះមានថវិកា ១២.០០០.០០០ (ដប់ពីរលានដុល្លាអាមេរិក) ក្នុងដំណាក់កាលសាងសង់រយៈ ពេល៤ឆ្នាំ និង៥.៥០០.០០០ (ប្រាំលាន ប្រាំរយលានដុល្លាអាមេរិក) សំរាប់រយៈពេល៤០ឆ្នាំ ក្នុងការប្រតិបត្តិផែនការណ៍ ការពារ បរិស្ថាន រួមទាំងកិច្ចដំណើរការគ្រប់គ្រងសំណល់រឹង រាវ... ។ល។

## ៩.៤ កម្មវិធីអង្កេតតាមដាន ត្រួតពិនិត្យការអនុវត្តវិធានការណ៍ការពារបរិស្ថាន

កម្មវិធីអង្កេតតាមដាន ត្រួតពិនិត្យការអនុវត្តវិធានការណ៏ការពារបរិស្ថាន (វិធានការកាត់បន្ថយការប៉ះពាល់បរិស្ថាន ដែលបានចែងក្នុងជំពូក ៧ និង៨ក្នុងការកំណត់ទំហំនៃការប៉ះពាល់អវិជ្ជមាន និង វិធានការកាត់បន្ថយ) នេះ និងបញ្ជាក់អំពីកិច្ចការដែលត្រូវអង្កេតតាមដាន និងត្រួតពិនិត្យគំរោងផងដែរ ។ ម៉្យាងវិញទៀត កម្មវិធីនេះនឹងប្រមើលឃ្លាំមើលសកម្មភាពការអនុវត្តគំរោង ដោយម្ចាស់គំរោងនៅក្នុងគ្រប់ដំណាក់កាលគំរោង។ កម្មវិធីនេះមានដូចតទៅ: (មានចែងក្នុងតារាងលេខ ៧១ ខាងក្រោម)

Draft

## តារាងលេខ ៧១: ផែនការត្រួតពិនិត្យតាមដានបរិស្ថាន

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងខ្សែបញ្ជូនអគ្គិសនី | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| • ធនធានរូបសាស្ត្រ | | | | |
| ១ | សណ្ឋានដី និង ប៉ានលេខា | - ពិនិត្យមើលការឈូសឆាយភ្លឺកន្លែងយកថ្មតើបានធ្វើជើងទេរត្រឹមត្រូវ ដាំស្មៅ ឬរុក្ខជាតិ សំរាប់ការពារការហូរច្រោះឬទេ និង ត្រួតពិនិត្យការពង្រាបដី ។<br>- ត្រួតពិនិត្យការពង្រាបដី នៅការដ្ឋានយកដី ថ្ម គ្រួស កន្លែងចោលសំណល់ដី និងថ្ម ពេលសាងសង់រួចមាន សំអាតធ្វើជើងទេជញ្ជាំង និងដាំដើមឈើឡើងវិញនៅកន្លែងទាំងនោះឬទេ ។ | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលព្រៃឈើ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៍គំរោងត្រូវធ្វើម្តង<br>- ក្នុងអំឡុងពេលសាងសង់គំរោង រយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ ការដ្ឋានសាងសង់ និងការដ្ឋានយកសំភារៈសំណង់ត្រូវធ្វើម្តង<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំ រយៈពេល ៣ ខែម្តង។ |
| ២ | ការហូរច្រោះ និង គុណភាពដី | - ពិនិត្យមើលការឈូសឆាយភ្លឺ តើបានធ្វើជើងទេរ ត្រឹមត្រូវ ដាំស្មៅ ឬរុក្ខជាតិសំរាប់ ការពារការហូរច្រោះហើយ តាមជញ្ជាំងទំនប់ និងមានធ្វើប្រឡាយ រួមទាំងរណ្តៅ សំរាប់ត្រងកករឬទេ ។<br>- ពិនិត្យមើលគុណភាពដីនៅខាងកន្លែងស្តុកសំភារៈ ស្តុកប្រេងឥន្ធនៈ សារធាតុគីមី រោងជាងមានការសំអាត និង គ្រប់គ្រងត្រឹមត្រូវល្អ ឬទេ ។<br>- ពិនិត្យមើលការដាំកំរាលរុក្ខជាតិ ការពារការហូរច្រោះដី នៅកន្លែងចោលដីស្អុយឬសំណល់ថ្ម កន្លែងយកដី ថ្ម គ្រួស និង ខ្សាច់ ។<br>- ពិនិត្យមើលកន្លែងចតគ្រឿងចក្រ និងកន្លែងស្តុកប្រេង និងសារធាតុគីមី ( ការកំពុប | - ក្រសួងបរិស្ថាន<br>- រដ្ឋបាលព្រៃឈើ<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | |

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងប្រព័ន្ធខ្សែបណ្តូច | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៣ | ប្រពន្ធ័ជលសាស្ត្រ | - សង្កេត តាមដានមើលភាពប្រែប្រួលនៃស្ទឹង ព្រែក អូរនៅក្នុងតំបន់គំរោងទាំងមូល<br>- ត្រួតពិនិត្យមើលការបញ្ចេញទឹកទៅខាងក្រោមទំនប់អាងទី១ មកអគារថាំពលទី១មានចំនួន ៦ម៣/វិនាទី មកខាងក្រោម ដើម្បីរក្សាជីវៈចំរុះនៃកំណាត់ស្ទឹងនៅចន្លោះទំនប់ទាំង២ឬទេ ។<br>- ត្រួតពិនិត្យមើលការបញ្ចេញទឹកទៅខាងក្រោមថាមពលទី២ ត្រង់ចំណុចក្បាលឆាយ ខាងលើទឹកភ្លៀវឱ្យលំហូរមានចំនួនមិនតិចជាង ០.៣ ម៣/វិនាទី (នៅរដូវប្រាំង)មកខាងក្រោម ដើម្បីរក្សាការពារជីវៈចំរុះនៃព្រៃកោងកាង និង ព្រែកកោះប៉ោ។<br>- ត្រួតពិនិត្យប្រព័ន្ធលូរទឹកស្អុយដែលបង្ហូរចូលក្នុងអូរ-ស្ទឹង (យកទឹកទៅវិភាគនៅកន្លែងចំណុចប្រសព្វមាត់ហូរចេញពីអូរទៅស្ទឹងកំចាយនោះរួចពិនិត្យលទ្ធផល យោងតាម ដែលម្ចាស់គំរោងស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវៈចំរុះរបស់ក្រសួងបរិស្ថាន ឬទេ) ។<br>- តើមានបង្កើតស្ថានីយ៍ជលសាស្ត្រ នៅកន្លែងចំណុចអាងទី១ ទី២ ដែរឬទេ? ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹក និង ឧតុនិយម<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- រដ្ឋបាលព្រៃឈើ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៍គំរោងត្រូវធ្វើ ម្តង។<br>- ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ការដ្ឋានសាង សង់និងការដ្ឋានយកសំភារៈសំណង់ត្រូវ ធ្វើម្តង ។<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំ រយៈពេល ៣ ខែម្តង។ |

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងផ្លូវខ្សែបណ្តាញ | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៤ | គុណភាពទឹក លើដី និង ក្រោមដី | - ពិនិត្យមើលបំរែបំរួលកំរិតកំពស់ទឹកក្រោមដីនៅក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យកាកសំណល់រឹងរាវកន្លែងរស់នៅ និងការិយាល័យរបស់គំរោង និងពិនិត្យមើលកន្លែងចតគ្រឿងចក្រនិងកន្លែងស្តុកប្រេងនិងសារធាតុគីមី (ការកំពុលសារធាតុទាំងនេះ) ។ មានការលេចជ្រាបចូលប្រភពទឹកក្រោមដីដែរឬទេ?<br>- ពិនិត្យមើលគុណភាពទឹកតាមរយៈពិសោធន៍គុណភាពស្ទឹងកំចាយ និងក្នុងអាងទាំងពីរដោយបញ្ជាក់ថា គុណភាពយោងតាមស្តង់ដាគុណភាពទឹក ក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវៈចំរុះរបស់ក្រសួងបរិស្ថាន ឬទេ? ។<br>- ធ្វើការតាមដានការករកើតនូវរុក្ខជាតិទឹកចង្រៃដូចជា ចក កំផ្លោក ពើក សារាយ ។ល។ នៅក្នុងអាងទី១ និងទី២ ។<br>- ពិនិត្យកន្លែងដាំស្មៅតាមឫដើមឈើតាមទីជំរាល កន្លែងចាក់សំណល់ដីនិងថ្ម តើរុក្ខជាតិទាំងនេះដុះបានល្អឬទេ ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងធនធានទឹក និង ឧតុនិយម<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- រដ្ឋបាលព្រៃឈើ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៍គំរោងត្រូវធ្វើ ម្តង ។<br>- ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ការដ្ឋានសាងសង់ និងការដ្ឋានយកសំភារៈសំណង់ត្រូវ ធ្វើម្តង ។<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំ រយៈពេល ៣ ខែម្តង ។ |
| ៥ | ការបំពុលខ្យល់ | - ត្រួតពិនិត្យមើលគុណភាពខ្យល់ក្នុងតំបន់គំរោង ដូចជា ផង់ធូលី កន្លែងបំផ្ទុះ កន្លែងយកដីកដី យកថ្ម ខ្សាច់ ភ្លើងឆេះព្រៃ ។ល ។<br>- ត្រួតពិនិត្យមើលការបញ្ចេញផ្សែងរបស់គ្រឿងចក្រ ។<br>- ត្រួតពិនិត្យការគ្រប់គ្រងកាកសំណល់រឹង-រាវរបស់ គំរោងមានភាយក្លិនមិនល្អឬទេ ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- រដ្ឋបាលព្រៃឈើ | - ក្នុងអំឡុងពេលសាងសង់គំរោងរយៈ ពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិនិងថែទាំ គំរោង រយៈពេល ៣ខែម្តង ។ |

Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងប្រព័ន្ធខ្សែបញ្ជូន | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៦ | ការបំពុលទឹក | - ត្រួតពិនិត្យព្រៃឈើកន្លែងដែលត្រូវលិច (មើលផែនទីទី២) បានកាប់សំអាតឬទេ មុនពេលដក់ទឹកក្នុងអាង ។<br>- ត្រួតពិនិត្យការគ្រប់គ្រងកាកសំណល់រឹង-រាវរបស់គំរោង ។<br>- ត្រួតពិនិត្យប្រព័ន្ធលូរទឹកស្អុយដែលបង្ហូរចូលក្នុងអូរ-ស្ទឹង (យកទឹកទៅវិភាគនៅកន្លែងចំណុចប្រសព្វមាត់លូហូរថ្លាក់ក្នុងអូរ ឬស្ទឹងរួចពិនិត្យលទ្ធផលយោង តាមស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវៈចំរុះ របស់ក្រសួង បរិស្ថាន ឬទេ) ។<br>- ធ្វើការតាមដានការករកើតនូវរុក្ខជាតិទឹកចង្រៃដូចជា ចក កំផ្លោក ពើក សារាយ ។ល។ នៅក្នុងអាងទី១ និងទី២ ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល<br>- ក្រសួងធនធានទឹក និង ឧតុនិយម<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាលប្រតិបត្តិនិងថែទាំគំរោងរយៈពេល ៣ខែម្តង ។ |
| ៧ | ការបំពុលដី | - ត្រួតពិនិត្យការគ្រប់គ្រងកាកសំណល់រឹង-រាវរបស់ គំរោង ។<br>- ត្រួតពិនិត្យកន្លែងស្តុកប្រេងឥន្ធនះ កន្លែងចតគ្រឿងចក្ររបស់គំរោង (ការកំពុបប្រេង និងថ្នាំគីមីទៅលើដីក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងតាមគន្លង់ខ្សែចម្លង) ។ | | |
| ៨ | សំលេង និង រំញ័រ | - ត្រួតពិនិត្យសំលេង និង រំញ័ររបស់រថយន្ត គ្រឿងចក្រ និង ការបំផ្ទុះក្នុងតំបន់គំរោង<br>- ត្រួតពិនិត្យពេលវេលាធ្វើការរបស់គំរោង ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | - ក្នុងអំឡុងពេលសាងសង់គំរោងរយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំគំរោងរយៈពេល ៣ខែម្តង ។ |

- ធនធានជីវសាស្ត្រ

Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងប្រព័ន្ធខ្សែបញ្ជូន | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ១ | ធនធានព្រៃឈើ និង ជំរកសត្វ | - ត្រួតពិនិត្យៈមើលសកម្មភាពបរបាញ់សត្វ និង ចរាចរឈើ និង សត្វព្រៃរបស់បុគ្គលិក កម្មករ គំរោង ។<br>- ត្រួតពិនិត្យសំលេងរបស់គ្រឿងចក្រ និង ពេលវេលាធ្វើការ ។<br>- ត្រួតពិនិត្យការរានដីព្រៃឈើក្នុងតំបន់ការពារ និងអភិរក្សយកធ្វើកម្មសិទ្ធិខុសច្បាប់ ។<br>- ត្រួតពិនិត្យលើតំបន់ដែលត្រូវកាប់សំអាតព្រៃឈើ នៅក្នុងអាងទាំង២ នៅតាមគន្លងខ្សែបញ្ជូនចរន្ត តើមានការកាប់ឈើរំលោភចូលតំបន់ព្រៃឈើផ្សេងទៀតឬទេ (ដោយប្រើ GPS ផ្ទៀងផ្ទាត់ជាមួយចំណុចនិយាមការនៃតំបន់ទាំងនោះ) ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- រដ្ឋបាលព្រៃឈើ<br>- អាជ្ញាធរដែនដី ពាក់ព័ន្ធ<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៍គំរោងត្រូវធ្វើម្តង<br>- ក្នុងអំឡុងពេលសាងសង់គំរោង រយៈពេល៣ខែម្តង ។<br>- ក្នុងដំណាក់កាលបញ្ចប់ការដ្ឋានសាងសង់ និងការដ្ឋានយកសំភារៈសំណង់ត្រូវធ្វើម្តង<br>- ក្នុងដំណាក់កាលប្រតិបត្តិ និងថែទាំ រយៈពេល ៣ ខែម្តង ។ |
| ២ | ជីវសាស្ត្រ សត្វព្រៃ និង មច្ឆជាតិ | - ត្រួតពិនិត្យមើលសកម្មភាពបរបាញ់សត្វរបស់បុគ្គលិក គំរោង ។<br>- ត្រួតពិនិត្យសំលេងរបស់គ្រឿងចក្រ ការបំផ្ទុះ និង ពេលវេលាធ្វើការ ។<br>- ត្រួតពិនិត្យ តាមដានប្រភេទ និងបរិមាណសត្វព្រៃ ត្រី ។<br>- ត្រួតពិនិត្យកន្លែងចញ្ចឹមត្រី ជិតផុតពូជ និងពិនិត្យកន្លែងដែលត្រូវ ព្រលែងចូលក្នុងតំបន់ក្បែរខាងមានលក្ខណៈជំរកធម្មជាតិប្រហែល ឬដូចដើមឬទេ ។ | | |
| • ធនធានសេដ្ឋកិច្ច និង សង្គម | | | | |
| ២ | ការរស់នៅ និង មុខរបររបស់សហគមន៍ មូលដ្ឋាន | - ត្រួតពិនិត្យការជ្រើសរើសបុគ្គលិករបស់ក្រុមហ៊ុន (ផ្តល់អាទិភាពឱ្យអ្នកភូមិជុំវិញតំបន់គំរោងទាំងស្រី ទាំងប្រុស) ។<br>- ត្រួតពិនិត្យតាមដានលើការជីវភាពអ្នកនេសាទក្នុងព្រែកកោះប៉ោ នៃភូមិកោះប៉ោ ភូមិនាងកុក និង ភូមិ១ មានការបាត់បង់ ឬរីកចំរើន ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគំរោងនេះ ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- អាជ្ញាធរដែនដីពាក់ព័ន្ធ | - ក្នុងអំឡុងពេលសាងសង់គំរោង រយៈពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិ និងថែទាំ គំរោង រយៈពេល ៣ខែម្តង ។ |
| ៣ | ប្រពៃណី វប្បធម៌ និងសាសនា | - ពិនិត្យតាមដានរាល់ការខុសឆ្គង និងអំពើល្មើសរបស់បុគ្គលិកក្រុមហ៊ុន ទៅលើ ប្រពៃណីទំនៀមទំលាប់ និងវប្បធម៌របស់ប្រទេសជាតិ និងរបស់ប្រជាជនមូលដ្ឋាន ។ | | |

Draft

| ល.រ | ធនធានបរិស្ថាន | សកម្មភាពត្រួតពិនិត្យតាមដាន ក្នុងតំបន់ហេដ្ឋារចនាសម្ព័ន្ធគំរោង និងប្រព័ន្ធខ្សែបញ្ជូន | ស្ថាប័នត្រួតពិនិត្យ | ពេលវេលាត្រួតពិនិត្យ |
|---|---|---|---|---|
| ៤ | ផ្លូវគមនាគមន៍ និងចរាចរ | - ត្រួតពិនិត្យការធ្វើចរាចរណ៍ និង ផ្លាកសញ្ញាល្បឿន តាមផ្លូវក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការថែទាំជួសជុលផ្លូវក្នុងតំបន់គំរោង ។<br>- ពិនិត្យការថែទាំផ្លូវ និងចរាចរណ៍នៃតំបន់ទេសចរណ៍ថ្មី ក្នុងតំបន់អាង ឬតំបន់ ក្បែរខាង (ប្រសិនបើមាន) ។<br>- ត្រួតពិនិត្យសំលេង និង រំញ័ររបស់រថយន្ត គ្រឿងចក្រ ក្នុងតំបន់គំរោង ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- មន្ទីរសាធារណការខេត្តពាក់ព័ន្ធ<br>- មន្ទីរទេសចរណ៍ខេត្តពាក់ព័ន្ធ<br>- អាជ្ញាធរដែនដីពាក់ព័ន្ធ | - ក្នុងពេលចាប់ផ្តើមអនុវត្តន៏គំរោងរយៈ ពេល ៣ខែម្តង ។<br>- ក្នុងអំឡុងពេលសាងសង់គំរោង រយៈ ពេល ៣ ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិ និងថែទាំគំរោងរយៈពេល ៣ខែម្តង ។ |
| ៥ | សុខភាពសាធារៈ | - ត្រួតពិនិត្យការថែរក្សាសុវត្ថិភាពនៅក្នុងតំបន់គំរោង។<br>- ត្រួតពិនិត្យការថែទាំសុខភាពរបស់បុគ្គលិកកម្មករគំរោង ។<br>- ត្រួតពិនិត្យមើលបរិក្ខារ និងថ្នាំពេទ្យ ។<br>- ត្រួតពិនិត្យលើការទប់ស្កាត់ជំងឺឆ្លងផ្សេងៗ ក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការធ្វើចរាចរ និង ផ្លាកសញ្ញាល្បឿន តាមផ្លូវក្នុងតំបន់គំរោង ។<br>- ត្រួតពិនិត្យការដោះសំអាតគ្រាប់មីន និងយុទ្ធភណ្ឌ័មិនទាន់ផ្ទុះពីតំបន់គំរោង ។ | - ក្រសួងបរិស្ថាន<br>- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>- មន្ទីរសុខាភិបាលខេត្តពាក់ព័ន្ធ<br>- អាជ្ញាធរដែនដី<br>- មន្ទីរសាធារណការខេត្តពាក់ព័ន្ធ | |
| ៦ | ហានិភ័យ | - ពិនិត្យតាមដានរាល់ហេតុការណ៍ ដែលអាចឱ្យមានការបាក់ទំនប់បាក់ភ្នំ ។<br>- ត្រួតពិនិត្យការថែរក្សា សន្តិសុខ និង សុវត្ថិភាព លើជាតិផ្ទុះ ជាតិឆេះ ។<br>- ពិនិត្យ និងទប់ស្កាត់ភ្លើងឆេះព្រៃ និងអំពើភេវរកម្ម ក្នុងតំបន់គំរោង ។ | - ក្រុមហ៊ុន<br>- ក្រសួងបរិស្ថាន<br>- ក្រសួងមហាផ្ទៃ<br>- រដ្ឋបាលព្រៃឈើ<br>- អាជ្ញាធរមូលដ្ឋានពាក់ពន្ធ័ | - ក្នុងអំឡុងពេលសាងសង់គំរោង រយៈ ពេល ៣ខែម្តង ។<br>- ក្នុងដំណាក់កាល ប្រតិបត្តិ និងថែទាំគំរោងរយៈពេល៣ខែម្តង ។ |

Draft

## ៩.៥ កម្មវិធីបណ្តុះបណ្តាល

កម្មវិធីបំពាក់បំប៉នក៏ជាកត្តាសំខាន់មួយនៅក្នុងផែនការគ្រប់គ្រងបរិស្ថានផងដែរ ដែលគំរោងត្រូវយកចិត្តទុកដាក់ ដើម្បីអនុវត្តន៍ផែនការរបស់គំរោងឱ្យបានជោគជ័យ។ ដើម្បីធ្វើឱ្យគំរោងនេះ មានការអភិវឌ្ឍន៍ប្រកបដោយស្ថេរភាពចាំបាច់ត្រូវមានធនធានមនុស្ស ដែលមានសមត្ថភាពគ្រប់គ្រាន់សំរាប់បំពេញការងារឱ្យបានរីកចំរើន និងសុក្រឹត្យត្រឹមត្រូវទាំងការងារបច្ចេកទេស និងការងារបរិស្ថាន ដូច្នេះម្ចាស់គំរោងនឹងរៀបចំឱ្យមានវគ្គអប់រំបំពាក់បំប៉នដល់បុគ្គលិក និងកម្មករ ជាពិសេសបុគ្គលិក-កម្មករកម្ពុជាដូចជា: ចំណេះដឹងបច្ចេកទេសសំរាប់ប្រើឬបញ្ជារគ្រឿងម៉ាស៊ីនគ្រប់ប្រភេទក្នុងពេលសាងសង់ និងដំណើរការគំរោង។ ចំណេះដឹងពីការការពារសុវត្ថិភាពជាចំបងពេលកំពុងបំពេញការងាររបស់គំរោង។ បំពាក់បំប៉ន និងផ្សព្វផ្សាយពីជំនាញបច្ចេកទេស ច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធ ការបង្កឱ្យមានគ្រោះ ថ្នាក់ជាយថាហេតុ ពីសកម្មភាពគំរោងទៅលើធនធានធម្មជាតិ និងសង្គម ។ អប់រំ និងផ្សព្វផ្សាយវិធីសាស្ត្រការពារជំងឺរាតត្បាតផ្សេងៗ ជាពិសេសជំងឺអេសដីជាដើម។ បំពាក់បំប៉នដល់បុគ្គលិក-កម្មករក្នុងការគ្រប់គ្រងសំណល់រឹង-រាវ និងអប់រំបំពាក់បំប៉នបុគ្គលិកក្នុងការប្រើប្រាស់ និងថែទាំប្រព័ន្ធអាងប្រព្រឹត្តកម្មសំណល់រាវ។ អប់រំពីអត្ថប្រយោជន៍នៃធនធានបរិស្ថានសំខាន់ៗ ដែលមាននៅក្នុងតំបន់សំរាប់តម្រូវការសង្គម ដូចជា ទឹក ដី ខ្យល់ ព្រៃឈើ សត្វព្រៃ ជាពិសេសធនធានធម្មជាតិនៃតំបន់ឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) ។ល។ អប់រំ ពីវិធីសាស្ត្រជួយការពារបរិស្ថានក្នុង-ជុំវិញតំបន់គំរោង និងចំណេះដឹងពីការអង្កេត តាមដានគំរោងដែលទាក់ទង ទៅនឹងបរិមាណ និងគុណភាពបរិស្ថានមានស្រាប់ ដែលនឹងត្រូវរង ការប៉ះពាល់ ដោយសារសកម្មភាពគំរោងនេះ ។ រប់រំដល់កម្មករក្នុង ការគ្រប់គ្រងវត្ថុធាតុដើមដែលជាសារធាតុគីមីសំរាប់ប្រើប្រាស់ក្នុងសង្វាក់ផលិតកម្មរបស់គំរោង។ ក្រុមហ៊ុននឹងជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពខ្ពស់នៅប្រទេសចិនមកជួយបង្ហាត់បង្រៀនដល់បុគ្គលិក-កម្មករគំរោង និងទទួលបន្ទុកចំណាយទាំងស្រុង។ ក្រុមហ៊ុននឹងផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមករវាងប្រទេសចិន និងកម្ពុជាដោយបញ្ជូនគណៈប្រតិភូទៅទស្សនកិច្ចសិក្សា និងកម្មសិក្សានៅប្រទេសចិន។

## ៩.៦ ការប៉ាន់ប្រមាណថវិកាសំរាប់កិច្ចការពារបរិស្ថាន

ការការពារបរិស្ថានក្នុងតំបន់គំរោង និងជុំវិញតំបន់គំរោង គឺមានសារៈសំខាន់ណាស់ ដើម្បីធានាឱ្យដំណើរការគំរោងមាននិរន្តរភាព។ ផ្អែកតាមផែនការនៃការគ្រប់គ្រងបរិស្ថានរបស់ក្រុមហ៊ុន និងផែនការត្រួតពិនិត្យ អង្កេតបរិស្ថានរបស់គណៈកម្មការចំរុះរបស់រាជរដ្ឋាភិបាលកម្ពុជានោះក្រុមហ៊ុននឹងត្រៀមថវិកាចំណាយសំរាប់កិច្ចការពារត្រួតពិនិត្យ និងអង្កេតបរិស្ថានសរុបចំនួន ១៧.៥០០.០០០ដុល្លារអាមេរិក(ដប់ប្រាំពីរលាន ប្រាំរយពាន់ដុល្លារអារមេរិក) ដូចមានរៀបរាប់លំអិតខាងក្រោម:

Draft

# តារាងលេខ ៧២ : ការប៉ាន់ប្រមាណថវិកាសំរាប់កិច្ចការពារបរិស្ថាន

## ផ្នែក១: ថវិកាចំណាយសំរាប់កាត់បន្ថយហេតុប៉ះពាល់សំខាន់ៗ នៃការសាងសង់

| ល.រ | ដំណាក់កាលអភិវឌ្ឍន៍ | ធ.បរិស្ថាន | ផលប៉ះពាល់នៅវាល | ប្រភេទនៃផលប៉ះពាល់ | គោលបំណងនៃការទប់ស្កាត់ | ថវិកាចំណាយ (USD) | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|
| 1 | ដំណាក់កាល សាងសង់ | ធនធានរូបសាស្ត្រ | ប្រព័ន្ធរបស់ទឹក | ការបំពុលទឹកដោយ សមាសធាតុគីមី | ក្រុមហ៊ុននឹងសាងសង់អាង ប្រព្រឹត្តកម្មសំណល់រាវ | 300,000 | អាងប្រព្រឹត្តកម្មសំរាប់ផលិតផលដំណាំ |
| 2 | | | | ការបំពុលទឹកដោយ សារធាតុបង្កជំងឺនៅ ក្នុងទន្លេ | ជំរុញអោយមានប្រព័ន្ធ អនាម័យ ដែលទាក់ទងទៅនិងកាត ព្វកិច្ចរបស់ អ្នកកុងត្រា | 200,000 | សំរាប់ការសាងសង់ ការដ្ឋាន និងជំរុំ |
| 3 | | | ប្រព័ន្ធរបស់ដី | ធូរលីដែលកើតឡើង ដោយសកម្មភាពសាង សង់ការដ្ឋាន | រៀបចំកាលវិភាគសមរម្យ និងសាង សង់ទំនប់ការពារធូរលីដី | 1,000,000 | ជញ្ជាំងទប់ និងជ្រាំង ជំរេលនៃរនាំងបាំង |
| 4 | | | | សំណឹកដីបន្ទាប់ពីស កម្មភាពសាងសង់ | សាងសង់ឃ្លាំងប្រេង និងប្រើប្រាស់ឧបករណ_ high-tech | 500,000 | ឃ្លាំងស្តុបកាកសំណល់ប្រេង និងអ្នកចូលរួប ជាមួយការងារ ស៊ីវិល |
| 5 | | ធនធានសេដ្ឋកិច្ចសង្គម | សង្គម | ប៉ះពាល់ទៅលើការ ប្រើប្រាស់ដីនៅការ ដ្ឋានសាងសង់ | បង្កើតអោយមាន នៅតំរូវការដីសប្បទាន ទាបបំផុត<br>ដោយមានសំណងសម រម្យ រួមមានការចំណាយការ ជ្រើសរើស និង បង្កើតដី លំនៅដ្ឋានបណ្តោះអាសន្ន | 100,000 | ការព្រឹក្សាទៅលើថវិកាចំណាយ |
| 6 | | | | | កែសម្រួលផ្លូវអោយប៉ះពាល់ទាបបំផុតទៅលើដីសប្បទាន<br>ជាលទ្ធផលខ្សែរបញ្ជូន ១០គ.ម ពីរោងចក្រ អគ្គិសនីទៅ Grid ។ | 100,000 | ការព្រឹក្សាទៅលើថវិកាចំណាយ |
| 7 | ដំណាក់កាលប្រតិបត្តិ (ការបញ្ចូលទឹកក្នុងអាង) | ធនធានជីវសាស្ត្រ | ប្រព័ន្ធផល ជាតិ | កាត់បន្ថយនៅលំហូរ របស់ទន្លេ | ហូរទៅអាងខាងក្រោម របស់គំរោងក្នុង ពេលសាង សង់ និងទឹកពេញអាង | 500,000 | ឧបករណ៍ដែលមានសមត្ថភាពក្នុង ការបូមខ្ពស់ |
| 8 | | | | | ល្បឿនទឹកហូរទាបបំផុត ៥ម៣ / វិនាទី អាចទប់ទល់ បាននៅរដូវប្រាំង | 500,000 | ការបង្កប់ប្រព័ន្ធ ទុយោដែកដើម្បីថែរក្សាចរន្តទឹកហូរ |
| 9 | | ធនធានសេដ្ឋកិច្ចសង្គម | សង្គម | ប៉ះពាល់ដល់ប្រភពចំណូលរបស់អ្នកភូមិ ដែលបានមកទិន្នផល ព្រៃឈើ | មានការចេញសំណង់ លើ ការបាតបង់ប្រាក់ ចំណូល | 500,000 | សំណង់ទៅអ្នកដែលជាប់ ពាក់ពាន់ឬភូមិ លើការបាត់បង់ ប្រាក់ចំណូល និងដំណាំ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 10 | | | | ប៉ះពាល់ទៅលើស្ថានីយ៍ផ្គត់ផ្គង់ទឹកក្រុងកំពត | ពិភាក្សាជារាជរដ្ឋាភិ បាល ដើម្បីផ្លូវទីតាំងស្ថានីយ៍បូម ទឹកទៅក្នុងអាងទី២ | 50,000 | ការព្រឹក្សាទៅលើថវិកាចំណាយ |
| 11 | | | | ប៉ះពាល់លើប្រភពប្រាក់ ចំណូល របស់អ្នកភូមិ ពីទេសចរណ៍ទឹកឈូ | មានការចេញសំណងលើ ការ បាត់បង់ប្រាក់ចំណូល | 500,000 | |
| 12 | | ធនធានរូបសាស្ត្រ | ប្រព័ន្ធរបបទឹក | ការប្រែប្រួលគុណភាព ទឹក | ក្រុមហ៊ុននឹងរក្សាការពារគុណ ភាពទឹកដោយ ឧបករណ៍រក្សាគុណភាពទឹក | 100,000 | ឧបករណ៍ និងសំភា រៈដែលចាំ បាច់ |
| 13 | | | | ការកាត់បន្ថយនៅបរិ មាណកករ នៅក្នុងទឹក ចេញពីអាង | មិនទាមទារ | | |
| 14 | | | | មានរយៈពេលវែងក្នុងការបង្ហូរ ទឹក anoxic | មានការប្រែប្រួលកំ ពស់ទឹក ច្រើន ទាំងចូល និងចេញ | | សាងសង់ប្រពន័បំបែក $O_2$ នៅ ត្រង់ទ្វាបញ្ចេញទឹក |
| 15 | | | | គ្រោះថ្នាក់ និងការបំពុលទឹក រយៈពេលវែង | ផែនការយុទ្ធសាស្ត្រ រយៈ ពេលវែងដើម្បីត្រួតពិនិត្យផ្ទៃ រងទឹកភ្លៀង | 200,000 | មានគំរោងផែន ការណ៍ និងការព្រឹក្សាយោបល់ លើថវិការ ចំណាយ |
| Sub-Total (1) | | | | | | 4,550,000 | |

## ផ្នែក២: ថវិកាចំណាយលើការទប់ស្កាត់ហេតុប៉ះពាល់ទៅលើតំបន់ព្រៃលិចទឹក និងផ្ទៃរងទឹកភ្លៀង

| ល.រ | ចំណាក់កាលអភិវឌ្ឍន៍ | ធ.បរិស្ថាន | ផលប៉ះពាល់នៅវាល | ប្រភេទនៃផលប៉ះពាល់ | គោលបំណងនៃការទប់ស្កាត់ | ថវិកាចំណាយ (USD) | កំណត់សំគាល់ |
|---|---|---|---|---|---|---|---|
| 1 | ដំណាក់កាលសាងសង់ | ធនធានជីវសាស្ត្រ | ប្រព័ន្ធដី ជាគ | មិនមានសញ្ញាណអំពី ហេតុប៉ះពាល់ដែលកើត ឡើងដោយមិន បានរំពឹងទុក | មិនទាន់បានទប់ស្កាត់ | | |
| 2 | | ធនធានសេដ្ឋកិច្ចសង្គម | សង្គម | ប៉ះពាល់ទៅលើការប្រើ ប្រាស់ដី | មានការចេញសំណងទាន់ ពេលវេលា និងការផ្តល់ដី | 3,500,000 | |
| 3 | បិទ (ការបញ្ចូលទឹកបំពេញអាង) | ធនធានជីវសាស្ត្រ | ប្រព័ន្ធដី ជាគ | បាត់បង់លំហូរតាមបែបធម្មជាតិ របស់ទន្លេ និង អូរ | មានការចេញសំណង ដោយបង្កើតជាមូលនិធិក | 400,000 | (មូលនិធិកដើម្បី ប្រើ) |
| 4 | | | | ការប្រែប្រួលគុណភាព ទឹក | មានការចេញសំណង ដោយបង្កើតជាមូល និធិក | 200,000 | |



Draft

| | | | | | | | |
|---|---|---|---|---|---|---|---|
| 5 | | | | ១ | តំបន់អភិរក្សក៏ដូចជាតំលៃ ជីវសាស្ត្រដែរ | 200,000 | |
| 6 | | | សត្វព្រៃ | ការប្រែប្រួលគុណភាព ទឹក | អភិរក្សជំរកសត្វ | 200,000 | កម្មវិធីជួយសង្គ្រោះ សត្វព្រៃ |
| 7 | | | | | ហាមប្រាមដល់កម្មករកុំ អោយសំលាប់ និងជួញដូរ សត្វព្រៃ | 50,000 | កម្មវិធីជួយសង្គ្រោះ សត្វព្រៃ |
| 8 | | | | | កម្មវិធីសំអាត និង កម្មវិធី ជួយសង្គ្រោះ សត្វព្រៃពេលបញ្ចូល ទឹកក្នុងអាង | 200,000 | កម្មវិធីជួយសង្គ្រោះ សត្វព្រៃ |
| 9 | | | សត្វព្រៃ | បង្កើតតំបន់ដីសើមថ្មី | គ្រប់គ្រងតំបន់ដី សើម និងអភិរក្ស ផលដែលមានស្រាប់ | 400,000 | ប្រតិបត្តិរយៈពេល ៤០ឆ្នាំ |
| 10 | | | | បង្កើតតំបន់ត្រីពងថ្មី | ថែរក្សាផ្លូវធ្វើចលនា របស់ត្រី និងអភិរក្ស អ្វីដែលមានស្រាប់ | 400,000 | |
| 11 | | | ប្រព័ន្ធ បរិស្ថាន | បាត់បង់សេដ្ឋកិច្ចធនធានដីទៅថ្ងៃ អនាគត់ (ឧទ្យានជាតិបូកគោ) | ចេញសំណង់លើតំបន់បៃតង ជុំវិញឧទ្យាន ជាតិ និងផ្តល់ មូលនិ ធិកសំរាប់ បរិស្ថាន | 4,000,000 | ប្រតិបត្តិរយៈពេល ៤០ឆ្នាំ |
| 12 | | ធនធានសេដ្ឋកិច្ចសង្គម | សង្គម | បាត់បង់ផលិតផលព្រៃ ឈើ | ហាមឃាត់ការកាប់ឈើ ដូចបានពិគ្រោះ យោបល់ជាមួយ នាយកដ្ឋាន | 2,000,000 | ការសំអាតអាង និងការកាប់ព្រៃ |
| 13 | | | | | កម្មវិធីប្រមូលអ្នកជាប់ទាក់ទងជាមួយ ការឈ្មួសឆាយ ផលដំណាំ | 100,000 | ការព្រឹក្សាទៅលើ ថវិកាចំណាយ |
| 14 | | | | ការប្រែប្រួលគុណភាព ទឹក | ភាពប្រែប្រួលការផ្គត់ផ្គង់ទឹក | 500,000 | |
| 15 | | | | បាត់បង់មុខរបរពីផលិតផល ធនធានព្រៃឈើ | រកកន្លែងដែលសម រម្យសំរាប់ ប្រជាពល រដ្ឋប្រកបមុខរបរ និងជ្រើសពួកគាត់ជាបុគ្គលិក | 400,000 | ការរៀបចំនេះនឹង មានជាច្រើន ផ្នែក |
| 16 | | ធនធានរូបសា ស្ត្រ | ប្រព័ន្ធបរិស្ថានទឹក | ការអណ្តែតកាកសំណល់លើទឹក | រៀបចំ និងអនុវត្តន៏ កម្មវិធី កំចាត់ សំណល់ | 100,000 | |
| 17 | | | | គុណភាពទឹកធ្លាកចុះ ពេលបញ្ចូលទឹកក្នុង អាង | ការសំអាតដំណាំបាយអូម៉ាស អាចកាត់ បន្ថយពេលវេលា | 200,000 | ប្រតិបត្តិរយៈពេល ៤០ឆ្នាំ |
| 18 | | | | កើនឡើងបរិមាណកករនៅ ក្នុងទឹក | ផែនការយុទ្ធសាស្ត្រ ដើម្បីត្រួត ពិនិត្យ ផ្ទៃរងទឹកភ្លៀង | 100,000 | ការព្រឹក្សាទៅលើ ថវិកាចំណាយ |
| Sub-Total (2) | | | | | | 12950000 | |
| **ថវិកាសរុបសំរាប់ EMP គឺ = (ផ្នែកទី១ + ផ្នែកទី២)= Sub-Total (1) +Sub-Total (2) =** | | | | | **17,500,000 USD** | | |

# ជំពូក ១០

# ការវិភាគសេដ្ឋកិច្ច និង តំលៃបរិស្ថាន

## Environmental Cost and Economy Analyses

Draft

# ជំពូកទី ១០

## ការវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន

## ១០.១ ការប៉ាន់ប្រមាណតំលៃបរិស្ថាន

ការវាយតំលៃបរិស្ថាន និងសង្គមលើគំរោងវិនិយោគសំរាប់អភិវឌ្ឍន៍វារីអគ្គិសនីកំចាយខេត្តកំពត របស់ក្រុមហ៊ុន Kamchay Sinohydro Hydroelectric Co,Ltd. ដែលក្រុមហ៊ុនបានឱ្យ SAWAC Consultants for Development ធ្វើការសិក្សាស្រាវជ្រាវ នោះ រួមមាន តំលៃបរិស្ថានរូបសាស្ត្រ បរិស្ថានធនធានធម្មជាតិ និងបរិស្ថានសង្គម ដើម្បីរកឱ្យឃើញថា គំរោង ត្រូវបំពេញបន្ថែមនូវតំលៃបរិស្ថាន លើការវិនិយោគនេះ ។

**តារាង ៧៣ : ការប៉ាន់ប្រមាណតម្លៃសេដ្ឋកិច្ចនៃការបាត់បង់ព្រៃឈើក្នុងតំបន់គំរោង:**

| Item | ការប៉ាន់ប្រមាណ (USD) | ទំហំ(ha.) | សរុប (USD) | ផ្សេងៗ |
|---|---|---|---|---|
| ព្រៃស្រោង | ៣៧៥ (១) | ១៤២២.១៦ | ៥៣៣៣១០ | |
| ព្រៃល្បាយឫស្សី | ៥៣.៦ (២) | ៤១៦ | ២២២៩៧.៦ | |
| សរុប(USD) | | | ៥៥៥៦០៧.៦ | |

*(១) ជាព័ត៌មានBaseline survey ដែលបានសិក្សា និងចេញផ្សាយដោយ CDRI ឆ្នាំ២០០៦*

*(២) មានបង្ហាញនៅក្នុងជំពូក២*

### ១០.១.១ ការប៉ាន់ប្រមាណតំលៃបរិស្ថានធនធានជលផល

ផ្អែកតាមការសិក្សាបរិមាណផលចាប់ និងតំលៃបច្ចុប្បន្នរបស់ត្រី យើងអាចប៉ាន់ប្រមាណប្រាក់ចំណូលពីការនេសាទដូចមានបង្ហាញក្នុងតារាង៧៦ខាងក្រោម :

**តារាង ៧៤: ការប៉ាន់ប្រមាណប្រាក់ចំណូលពីការនេសាទប្រភេទត្រីមានប្រភពពីតំបន់គំរោងនៅពេលទឹកជំនន់ផ្នែកខាងក្រោមតំបន់គំរោង**

| [redacted] | | ភាគរយ នៃបរិមាណផលចាប់ (កំណត់ ដោយអ្នកនេសាទ ចំនួន៦១ គ្រួសារ) | [redacted] | |
|---|---|---|---|---|
| ឆ្នាំសិក្សា | បរិមាណផលចាប់តាមបណ្តាឆ្នាំ២០១០ | | តំលៃបច្ចុប្បន្ន គិតមធ្យម | ចំណូលសរុប (ដុល្លារអាមេរិក) |
| (១) | (២) | (៣) | (៤) | (៥) |
| ២០០៦ | ១៥៤៦៤ | - | ១.៨៧$/គក្រ | ២៨.៩១៧,៦៨ |
| ២០០៧ | ១១៥៥៨ | ៧៥ % នៃឆ្នាំ២០០៦ | ១.៨៧$/គក្រ | ២១.៦៨៨,២៦ |
| ២០០៨ | ១១០១៨ | ៩៥ % នៃឆ្នាំ២០០៧ | ១.៨៧$/គក្រ | ២០.៦០៣,៦៦ |
| ២០០៩ | ១១៥៦៩ | ១០៥% នៃឆ្នាំ២០០៨ | ១.៨៧$/គក្រ | ២១.៦៣៤,០៣ |
| ២០១០ | ៧៩១ | ៦.៦ % នៃឆ្នាំ២០០៩ | ១.៨៧$/គក្រ | ១.៤៧៩,១៧ |
| ចំណូលអប្បបរមា ឆ្នាំ២០១០ | | | | ១.៤៧៩,១៧ |
| ចំណូលអតិបរមា ឆ្នាំ២០០៦ | | | | ២៨.៩១៧,៦៨ |
| ចំណូលមធ្យម/ឆ្នាំ គិតពីឆ្នាំ២០០៧-២០០៩ | | | | ២១.៣០៨,៦៥ |

Draft

**តារាងទី ៧៥: ការប៉ាន់ប្រមាណប្រាក់ចំណូលពីការនេសាទត្រីក្នុងតំបន់គំរោង**

| ការប៉ះពាល់លើប្រាក់ចំណូលនៃមុខរបរនេសាទអាជីព នេសាទនៅក្នុងតំបន់គំរោង | | ភាគរយ នៃបរិមាណផលចាប់ (កំណត់ដោយអ្នកនេសាទចំនួន៦១ គ្រួសារ) | ការបាត់បង់ប្រាក់ចំណូល | |
|---|---|---|---|---|
| ឆ្នាំ | បរិមាណផលចាប់ត្រីតាមបណ្ដាឆ្នាំ | | តំលៃបច្ចុប្បន្នគិតមធ្យម | តំលៃសរុប (ដុល្លារអាមេរិក) |
| (១) | (២) | (៣) | (៤) | (៥) |
| ២០០៦ | ១០.៩៧៩ គ.ក្រ | - | ២.៣៨$/គក្រ | ២៥.១៧៨,០២ |
| ២០០៧ | ១០.០៥០ គ.ក្រ | ៩៥% នៃឆ្នាំ២០០៦ | ២.៣៨$/គក្រ | ២៣.៩១៩,០០ |
| ២០០៨ | ៩.០៤៥ គ.ក្រ | ៩០% នៃឆ្នាំ២០០៧ | ២.៣៨$/គក្រ | ២១.៥២៧,១០ |
| ២០០៩ | ៨.៥៩៣ គ.ក្រ | ៩៥% នៃឆ្នាំ២០០៨ | ២.៣៨$/គក្រ | ២០.៤៥១,៣៤ |
| ២០១០ | ៦.៣៨៤ គ.ក្រ | ៨៥% នៃឆ្នាំ២០០៩ | ២.៣៨$/គក្រ | ១៥.១៩៣,៩២ |
| ចំណូលអប្បបរមាឆ្នាំ២០១០ | | | | ១៥.១៩៨.៩២ |
| ចំណូលអតិបរមាឆ្នាំ២០០៦ | | | | ២៥.១៧៨,០២ |
| ចំណូលមធ្យម/ឆ្នាំ គិតពីឆ្នាំ២០០៧-២០០៩ | | | | ២១.៩៦៥,៨១ |

Draft

**តារាង ៧៦: ការប៉ាន់ប្រមាណប្រាក់ចំណូលពីការនេសាទត្រីអាជីព នៅព្រែកកំចាយ និងដែស្ទឹងកែវ**

| [redacted] | | ភាគរយ នៃបរិមាណផលចាប់ (កំណត់ដោយអ្នកនេសាទ ចំនួន ៦១ គ្រួសារ | [redacted] | |
|---|---|---|---|---|
| សំរង់ស្ថិតិប្រចាំឆ្នាំ | បរិមាណផលចាប់តាមបណ្ដាឆ្នាំ | | តំលៃបច្ចុប្បន្នគិតមធ្យម | តំលៃសរុប (ដុល្លារអាមេរិក) |
| (១) | (២) | (៣) | (៤) | (៥) |
| ២០០៦ | ២៥.៤៣៣ គ.ក្រ | - | ២.៨$/គក្រ | ៦៣.៥៨២,៥០ |
| ២០០៧ | ២៤.១៩៩.៤៩ គ.ក្រ | ៩៥,២០% នៃឆ្នាំ២០០៦ | ២.៨$/គក្រ | ៦០.៤៩៨,៧៣ |
| ២០០៨ | ២១.៩០០.០៥ គ.ក្រ | ៩០.៥០% នៃឆ្នាំ២០០៧ | ២.៨$/គក្រ | ៥៤.៧៥០,១៣ |
| ២០០៩ | ១៨.៧៧៩,២៩ គ.ក្រ | ៨៥.៧៥% ទៃឆ្នាំ២០០៨ | ២.៨$/គក្រ | ៤៦.៩៤៨,២៣ |
| ២០១០ | ១៥.៤៩៩ គ.ក្រ | ៨២.៥៣% នៃឆ្នាំ២០០៩ | ២.៨$/គក្រ | ៣៨.៧៤៧,៥០ |
| ចំណូលអប្បបរមា ឆ្នាំ២០១០ | | | | ៣៨.៧៤៧,៥០ |
| ចំណូលអតិបរមា ឆ្នាំ២០០៦ | | | | ៦៣.៥៨២,៥០ |
| ចំណូលមធ្យម/ឆ្នាំ គិតពីឆ្នាំ ២០០៧-២០០៩ | | | | ៥៤.០៦៥,៦៩ |

[redacted]

| | | | | |
|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |

| | | | | |
|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] ក្នុងដំណាក់កាល សាងសង់គំរោង | [redacted] | | | |
| [redacted] | [redacted] | | | |

## ១០.១.២ ការប៉ាន់ប្រមាណតំលៃបរិស្ថានសេដ្ឋកិច្ច_សង្គម

**តារាង៧៨ : ការប្រែប្រួលភ្ញៀវទេសចរមកកំសាន្តតំបន់រមណីយដ្ឋានទឹកឈូរ ពីឆ្នាំ២០០៦_២០១០**

| តារាងបង្ហាញពីបំរែបំរួលនៃភ្ញៀវទេសចរនៅក្នុងរមណីយដ្ឋានទឹកឈូ ពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ | | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ភ្ញៀវទេសចរបរទេស | ភាគរយ % | កើនឬថយធៀបឆ្នាំមុន | ភ្ញៀវទេសចរក្នុងស្រុក | ភាគរយ % | កើនឬថយធៀបឆ្នាំមុន |
| 2006 | 2333 | | | 275644 | | |
| 2007 | 3084 | 132.19 % | +32.19 % | 238002 | 86.34 % | -13.66 % |
| 2008 | 2809 | 91.08 % | -8.92 % | 256875 | 107.93 % | +7.93 % |
| 2009 | 4195 | 149.34 % | +49.34 % | 176563 | 68.73 % | -31.27 % |
| 2010 | 1884 | 44.91 % | -55.09 % | 67658 | 38.32 % | -61.68 % |
| សំគាល់: (+) ចំនួនភ្ញៀវកើនឡើង, (-) ចំនួនភ្ញៀវថយចុះ | | | | | | |

**តារាង៧៩: ចំណូលប្រចាំឆ្នាំរបស់ភ្ញៀវទេសចរ មកកំសាន្តតំបន់រមណីយដ្ឋានទឹកឈូរ ពីឆ្នាំ២០០៦_២០១០**

| ប្រភេទ | ភ្ញៀវទេសចរបរទេស | | | ភ្ញៀវទេសចរក្នុងស្រុក | | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ឆ្នាំ | ចំនួនភ្ញៀវ | ចំណូល | ឆ្នាំ | ចំនួនភ្ញៀវ | ចំណូល | ចំនួនភ្ញៀវ | ចំណូល |
| | 2006 | 2333 | $ 104,985.00 | 2006 | 275644 | $ 2,756,440.00 | 277,977 | $ 2,861,425.00 |
| | 2007 | 3084 | $ 138,780.00 | 2007 | 238002 | $ 2,380,020.00 | 241,086 | $ 2,518,800.00 |
| | 2008 | 2809 | $ 126,405.00 | 2008 | 256875 | $ 2,568,750.00 | 259,684 | $ 2,695,155.00 |
| | 2009 | 4195 | $ 188,775.00 | 2009 | 176563 | $ 1,765,630.00 | 180,758 | $ 1,954,405.00 |
| | 2010 | 1884 | $ 84,780.00 | 2010 | 67658 | $ 676,580.00 | 69,542 | $ 761,360.00 |
| អតិបរមា | 2009 | 4195 | $ 188,775.00 | 2006 | 275644 | $ 2,756,440.00 | 277,977 | $ 2,861,425.00 |
| អប្បបរមា | 2010 | 1884 | $ 84,780.00 | 2010 | 67658 | $ 676,580.00 | 69,542 | $ 761,360.00 |
| មធ្យម | | 2861 | $ 128,745.00 | | 202948 | $ 2,029,484.00 | 205,809 | $ 2,158,229.00 |

**តារាង៨០: បំរែបំរួលចំណូលប្រចាំឆ្នាំរបស់ភ្ញៀវទេសចរ មកកំសាន្តតំបន់រមណីយដ្ឋានទឹកឈូរ ពីឆ្នាំ២០០៦_២០១០**

| ឆ្នាំ | សរុប | | |
|---|---|---|---|
| | ចំនួនភ្ញៀវ | ចំណូល | ការថយចុះប្រាក់ចំណូលធៀប២០០៦ |
| 2006 | 277,977 | $ 2,861,425.00 | |
| 2007 | 241,086 | $ 2,518,800.00 | $ 342,625.00 |
| 2008 | 259,684 | $ 2,695,155.00 | $ 166,270.00 |
| 2009 | 180,758 | $ 1,954,405.00 | $ 907,020.00 |
| Average of 2007-2009 | | | $ 471,971.67 |
| 2010 | 69,542 | $ 761,360.00 | $ 2,100,065.00 |

Draft

## ១០.១.៣ ការវិភាគតំលៃ នៃផលប៉ះពាល់បរិស្ថានអវិជ្ជមាន

[redacted]

| [redacted] | [redacted] | [redacted] | | [redacted] |
|---|---|---|---|---|
| [redacted] | [redacted] | [redacted] | | |
| [redacted] | [redacted] | [redacted] | | [redacted] |
| [redacted] | [redacted] | [redacted] | | [redacted] |
| [redacted] | | | | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | | [redacted] |
| [redacted] | [redacted] | [redacted] | | [redacted] |
| [redacted] | [redacted] | | | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |

Draft

**បញ្ជាក់ :**

- លទ្ធផលនៃការជ្រើសរើសតំលៃ Carbon Dioxide ក្នុងអង្គសិក្ខាសាលា ថ្ងៃ២៥ ខែមីនា ឆ្នាំ២០១១ បានកំណត់យកតំលៃអប្បបរមា ៥.៧ ដុល្លារ ព្រោះថា ប្រទេសកម្ពុជាមិនអាចកែច្នៃបានដោយខ្លួនឯងទេ គឺត្រូវពឹងផ្អែកលើអ្នកវិនិយោគ ។
- ការកំណត់តំលៃព្រៃឈើ គឺដកស្រង់ចេញពីឯកសារ Natural forest benefits and economic analysis of natural forest conversion in Cambodia – working papaer 33, December 2006.
- ការថយចុះ ប្រាក់ចំណូលនេសាទគ្រួសារ ក្នុងដំណាក់កាលសាងសង់ឆ្នាំ២០០៧ ដល់ឆ្នាំ២០០៩ អង្គសិក្ខាសាលាសម្រេចគិតជាមធ្យមព្រោះគំលាតវាតូច ចំពោះការថយចុះប្រាក់ចំណូលឆ្នាំ២០១០វាមានគំលាតខ្ពស់ត្រូវបូកបញ្ចូលជាក់ស្តែង ។ រីឯការថយចុះ ប្រាក់ចំណូលគ្រួសារនេសាទ ក្រោយការសាងសង់ មានផលប៉ះពាល់ខ្លាំងលើគុណភាពទឹក ក្នុងរយៈពេល

៣ឆ្នាំដំបូង ហើយប្រាក់ចំណូលនេះវានឹងកើនឡើងវិញបន្ទាប់ពី៣ឆ្នាំ ដំបូងនេះ ដោយសារ ក្រុមហ៊ុន បានធ្វើទំនប់ផ្នែកខាងក្រោម អភិរក្សមេព្វជត្រី និងបង្កើនធនធានជលផលឡើងវិញ។

- ដូចគ្នាដែរ ចំពោះការថយចុះប្រាក់ចំណូលពីភ្ញៀវទេសចរ នៅឆ្នាំ២០០៧-២០០៩ អង្គសិក្ខាសាលាសម្រេច គិតជាមធ្យម ព្រោះគំលាតវាតូច ចំពោះការថយចុះប្រាក់ចំណូលឆ្នាំ២០១០ វាមានគំលាតខ្ពស់ត្រូវបូកបញ្ចូលជាក់ស្តែង។ រីឯការថយចុះប្រាក់ចំណូលពីភ្ញៀវទេសចរណ៍ ក្រោយការសាងសង់ នឹងមានផលប៉ះពាល់ខ្លាំងលើគុណភាពទឹកក្នុងរយៈពេល៣ឆ្នាំដំបូង គឺចំនួនភ្ញៀវទេសចរប្រហាក់ប្រហែល ឆ្នាំ២០១០ដែរ។ ប្រាក់ចំណូលនេះ នឹងកើនឡើងវិញ នៅពេលក្រុមហ៊ុនពង្រីកតំបន់ទេសចរណ៍ក្នុងតំបន់គំរោងឡើងវិញ (ការលើកឡើង របស់តំណាងក្រុមហ៊ុន Sinohydro ក្នុង សិក្ខាសាលាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១)។

**<u>តារាង ៨២:</u> ផលប៉ះពាល់អវិជ្ជមាន លើតំលៃបរិស្ថាន ក្នុងការវិនិយោគគំរោងវារីអគ្គិសនីកំចាយ**

[redacted]

| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | |
| [redacted] | [redacted] | [redacted] | [redacted] | |
| | [redacted] | [redacted] | | |

**<u>សំគាល់:</u>** *ចំណុចទី៤ក្រុមហ៊ុនបានទូទាត់សំណងរួចរាល់ហើយ*

## ១០.២ ផលចំណេញ ពីគំរោង

### ១០.២.១ ហេដ្ឋារចនាសម្ព័ន្ធ ដែលបានទទួល និងគ្រោងទទួលពីគំរោង

គំរោងនេះ ក្រុមហ៊ុនបានសាងសង់ផ្លូវបីខ្សែ រួមមានប្រភេទ Concrete Road ( Width = 6m, Length = 12.50Km ) ប្រភេទ New laterite road ( Width = 8m, Length= 8.02 Km, ប្រភេទ New temperary laterite road ( Width = 4m, Length = 13.83 km) និង ប្រភេទ Rehabilitation laterite road ( Width = 8, Length = 7.40 km ) ។

**តារាង ៨៣: ក្រាក់សាងសង់ផ្លូវ**

Roads construction specification of Kamchay BOT Project by SINOHYDRO

| No. | Name | Length (Km) | Width | Time of completion | Construction cost (USD) | Remark |
|---|---|---|---|---|---|---|
| 1 | L8 Road | 5 | 6m | 2009.4 | 880,000 | From No.3 NR to Quarry |
| 2 | L6 Road | 10 | 6m | 2010.3 | 2,200,000 | From Site to No.3 NR |
| 3 | Permanent road at Site | 7 | 6m | 2011.11 | 5,000,000 | Entrance to Site and permanant traffic at Site;Cost includes slope treatment and protection measure |
| 4 | Temporary road at Site | 10 | 6m | 2007.9 | 850,000 | For construction use |
| 5 | 3# Road (between L6 and L8) | 14 | 6m | 2010.3 | 2,300,000 | |
| 6 | Total | 46 | | | 11,230,000 | |

- ក្រុមហ៊ុននឹងពង្រីកតំបន់ទេសចរណ៍ នៅក្នុង និងជុំវិញតំបន់គំរោង និងជួយដល់ហេដ្ឋារចនាសម្ព័ន្ធសង្គមផ្សេងទៀត ។
- ប្រជាពលរដ្ឋនឹងទទួលបានភ្លើងប្រើប្រាស់ដោយតម្លៃថោក ។
- កាត់បន្ថយការកាប់បំផ្លាញព្រៃឈើ ដោយប្រជាពលរដ្ឋប្តូរទំលាប់ឈប់ប្រើអុសសំរាប់ចំអិនមកប្រើប្រាស់អគ្គិសនីវិញ ។

## ១០.២.២ តំលៃសំណងលើផលប៉ះពាល់ផ្នែកសង្គម

គំរោងនេះក្រុមហ៊ុនបានចេញសំណងលើផលប៉ះពាល់ផ្នែកសង្គមរួមមាន:

- សំណងផលប៉ះពាល់លើចំការ ដីស្រែ ដំណាំ និងជួលដីជុំវិញការដ្ឋានយកថ្មសរុប USD3,500,000 ក្នុងនោះUSD 3,348,900 ជាសំណងពិតប្រាកដនិង USD 151,100 ចំណាយ ផ្សេងៗ ។

## ១០.២.៣ ថវិកាសំរាប់កិច្ចគាំពារគំរោងបរិស្ថាន

គំរោងស្តារបរិស្ថាន ១២.០០០.០០០ សំរាប់ដំណាក់កាលសាងសង់រយៈពេល ៤ឆ្នាំ និង ៥.៥០០.០០០ ដុល្លារអាមេរិក សំរាប់ ដំណាក់កាលក្រោយសាងសង់ រយៈពេល ៤០ឆ្នាំ ។

ក្រៅពីនេះក្រុមហ៊ុននឹងសាងសង់ទំនប់នៅផ្នែកខាងក្រោមទំនប់ទីពីរ ដើម្បីអភិរក្សត្រីពូជ ដែលមានប្រភពពីតំបន់គំរោង និងតំបន់ជុំវិញគំរោង ។ ផ្តល់ត្រីពូជក្នុងស្រុកប្រលែងចូលក្នុងតំបន់អភិរក្ស និងជុំវិញតំបន់គំរោង រយៈពេល១០ឆ្នាំៈ ចំនួន ១០០.០០០ក្បាល ក្នុង ១ឆ្នាំ គិតជាតំលៃ [redacted]

គំរោងនឹងជួយឧបត្ថម្ភសំរាប់មន្ត្រីជលផល ០៤រូប ក្នុងការអភិរក្សធនធានជលផល ក្នុងតំបន់ដែលក្រុមហ៊ុននឹងសាងសង់ទំនប់អាងអភិរក្សត្រី ផ្នែកខាងក្រោមទំនប់ទី២ ក្នុងម្នាក់ ៣០០ដុល្លារ/ខែ សរុប ១៤.៤០០ ដុល្លារអាមេរិក/ឆ្នាំ (៣០០គុណ ១២ខែ គុណ ៤នាក់ = ១៤.៤០០ ដុល្លារអាមេរិក/ឆ្នាំ) ។

គំរោងនឹងជួយឧបត្ថម្ភសំរាប់អនុរក្សព្រៃឈើ(បរិស្ថាន) ០៥រូប ក្នុងការអភិរក្សធនធានព្រៃឈើជុំវិញ និងក្នុងតំបន់គំរោង ក្នុងម្នាក់៣០០ដុល្លារ/ខែ សរុប ១៨.០០០ ដុល្លារអាមេរិក/ឆ្នាំ (៣០០គុណ ១២ខែ គុណ ៥ នាក់ = ១៨.០០០ ដុល្លារអាមេរិក /ឆ្នាំ) ។

ថវិកាសំរាប់ការដាំព្រៃឈើឡើងវិញ នៅជុំវិញ និងក្នុងតំបន់គំរោង រយៈពេល២០ឆ្នាំ ចំនួន ៤.០០០.០០០ ដុល្លារអាមេរិក ។

Draft

**តារាង ៨៤: ការវិភាគលើតម្លៃស្តារបរិស្ថាននៅក្នុងតំបន់កំពេង (ដាំប្រភេទឈើ រយៈពេលខ្លី ២០០០ ហ.ត, និងសង់ទំនប់អាងជំរកត្រី**

[redacted]

Draft

**<u>បញ្ជាក់:</u>** គំរោងស្តារបរិស្ថានតាមរយៈការដាំដើមឈើរយៈពេលខ្លីលើផ្ទៃដី ២០០០ហ.ត ក្នុងតម្លៃ ៤ លានដុល្លារ នៅជុំវិញតំបន់គំរោង ដែលបាត់បង់ព្រៃឈើ និងការសាងសង់ទំនប់អាងជំរកត្រី ពូជប្រវែង៤០០ម. ក្នុងតម្លៃ៨០០.០០០ ដុល្លារនៅផ្នែកខាងក្រោមទំនប់ទីពីរនៃវារីអគ្គិសនី នឹងធ្វើឱ្យបរិស្ថានធនធានព្រៃឈើ និងមច្ឆជាតិមានលំនឹងឡើងវិញ ដោយសារការប្រមូលផលិតផល ព្រៃឈើ និងត្រី ក្រោយពេលសាងសង់ គំរោងវារីអគ្គិសនីកំចាយបាន១០ឆ្នាំ បើគិតជាទឹកប្រាក់ចំណេញ USD28,048,794 ដូចតារាងខាងលើ។

**<u>តារាង ៨៥:</u> ការវិភាគ ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសំរាប់គំរោង BOOT**

| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | | [redacted] | |
| [redacted] | [redacted] | [redacted] | [redacted] | |
| [redacted] | [redacted] | [redacted] | [redacted] | |
| [redacted] | [redacted] | [redacted] | [redacted] | |
| [redacted] | [redacted] | [redacted] | [redacted] | |
| [redacted] | [redacted] | [redacted] | [redacted] | |

## ១០.៣ ការវិភាគសេដ្ឋកិច្ចសំរាប់ជំរើសគំរោង BOOT

### តារាង ៨៦: សង្ខេបនៃការវិភាគសេដ្ឋកិច្ចសរាប់គំរោង Build-Operation-Own-Tranfer (BOOT)

**Hydroelectric Power Project**
**BOOT Option: Kamchay Hydro Developers Inc. (KHDI)**

**Balance Sheet (US$ '000)**

| Calendar Year | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| Assets | | | | | | | | | | |
| Current Assets | | | | | | | | | | |
| Cash | 20088 | 23273 | 23292 | 22378 | 22376 | 22330 | 22252 | 21244 | 21147 | 21456 |
| Accounts receivable | 4031 | 4128 | 4227 | 4328 | 4432 | 4538 | 4647 | 4759 | 4873 | 4990 |
| Total Current Assets | **24119** | **27401** | **27519** | **26706** | **26808** | **26868** | **26899** | **26003** | **26020** | **26446** |
| Fixed Assets | | | | | | | | | | |
| Opening Book Value | 274356 | 259616 | 244877 | 230137 | 215398 | 200658 | 188751 | 176843 | 164936 | 153028 |
| Depreciation | 14740 | 14740 | 14740 | 14740 | 14740 | 11907 | 11907 | 11907 | 11907 | 11907 |
| Net Fixed Assets | **259616** | **244876** | **230137** | **215397** | **200658** | **188751** | **176844** | **164936** | **153029** | **141121** |
| Total Assets | **283735** | **272277** | **257656** | **242103** | **227466** | **215619** | **203743** | **190939** | **179049** | **167567** |
| Liabilities | | | | | | | | | | |
| Current Liabilities | | | | | | | | | | |
| Bank Overdraft | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Accounts payable | 641 | 657 | 672 | 688 | 705 | 722 | 739 | 757 | 775 | 794 |
| Total current liabilities | **641** | **657** | **672** | **688** | **705** | **722** | **739** | **757** | **775** | **794** |
| Long term Liabilities | | | | | | | | | | |
| Deferred Income Tax | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Long term loan | 182507 | 166946 | 151385 | 135824 | 122013 | 108534 | 95055 | 81576 | 69847 | 58118 |
| Current maturity | 15561 | 15561 | 15561 | 13811 | 13479 | 13479 | 13479 | 11729 | 11729 | 11493 |
| Total long term loans | **166946** | **151385** | **135824** | **122013** | **108534** | **95055** | **81576** | **69847** | **58118** | **46625** |
| Total Long term Liabilities | 166946 | 151385 | 135824 | 122013 | 108534 | 95055 | 81576 | 69847 | 58118 | 46625 |
| Total Liabilities | **167587** | **152042** | **136496** | **122701** | **109239** | **95777** | **82315** | **70604** | **58893** | **47419** |
| Equity | | | | | | | | | | |
| Share Capital | | | | | | | | | | |
| Preferred Shares | 64079 | 62258 | 58800 | 55341 | 51882 | 48423 | 44964 | 41506 | 38047 | 34588 |
| Common Shares | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 |
| Total Shares Capital | **101623** | **99802** | **96344** | **92885** | **89426** | **85967** | **82508** | **79050** | **75591** | **72132** |

Draft

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| Retained Earnings | 14524 | 20433 | 24816 | 26517 | 28801 | 33875 | 38919 | 41285 | 44564 | 48016 |
| **Total Equity** | **116147** | **120235** | **121160** | **119402** | **118227** | **119842** | **121427** | **120335** | **120155** | **120148** |
| **Total Liabilities and Equity** | **283734** | **272277** | **257656** | **242103** | **227466** | **215619** | **203742** | **190939** | **179048** | **167567** |
| **Calendar Year** | 2021 | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 |
| | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 |
| Assets | | | | | | | | | | |
| Current Assets | | | | | | | | | | |
| Cash | 20367 | 20190 | 17774 | 17678 | 17567 | 17442 | 17301 | 14364 | 14364 | 14364 |
| Accounts receivable | 5110 | 5232 | 5358 | 5487 | 5618 | 5753 | 5891 | 6033 | 6177 | 6326 |
| Total Current Assets | **25477** | **25422** | **23132** | **23165** | **23185** | **23195** | **23192** | **20397** | **20541** | **20690** |
| Fixed Assets | | | | | | | | | | |
| Opening Book Value | 141121 | 134467 | 127814 | 121160 | 114506 | 107853 | 101199 | 94545 | 87892 | 81238 |
| Depreciation | 6654 | 6654 | 6654 | 6654 | 6654 | 6654 | 6654 | 6654 | 6654 | 6654 |
| Net Fixed Assets | **134467** | **127813** | **121160** | **114506** | **107852** | **101199** | **94545** | **87891** | **81238** | **74584** |
| Total Assets | **159944** | **153235** | **144292** | **137671** | **131037** | **124394** | **117737** | **108288** | **101779** | **95274** |
| Liabilities | | | | | | | | | | |
| Current Liabilities | | | | | | | | | | |
| Bank Overdraft | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Accounts payable | 813 | 832 | 852 | 873 | 894 | 915 | 937 | 960 | 983 | 1006 |
| Total current liabilities | **813** | **832** | **852** | **873** | **894** | **915** | **937** | **960** | **983** | **1006** |
| Long term Liabilities | | | | | | | | | | |
| Deferred Income Tax | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Long term loan | 46625 | 36882 | 27139 | 21711 | 16283 | 10855 | 5428 | 0 | 0 | 0 |
| Current maturity | 9743 | 9743 | 5428 | 5428 | 5428 | 5428 | 5428 | 0 | 0 | 0 |
| Total long term loans | **36882** | **27139** | **21711** | **16283** | **10855** | **5427** | **0** | 0 | 0 | 0 |
| Total Long term Liabilities | 36882 | 27139 | 21711 | 16283 | 10855 | 5427 | 0 | 0 | 0 | 0 |
| Total Liabilities | **37695** | **27971** | **22563** | **17156** | **11749** | **6342** | **937** | **960** | **983** | **1006** |
| Equity | | | | | | | | | | |
| Share Capital | | | | | | | | | | |
| Preferred Shares | 31129 | 27670 | 24212 | 20753 | 17294 | 13835 | 10376 | 6918 | 3459 | |
| Common Shares | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 |
| Total Shares Capital | **68673** | **65214** | **61756** | **58297** | **54838** | **51379** | **47920** | **44462** | **41003** | **37544** |
| Retained Earnings | 53576 | 60050 | 59973 | 62218 | 64451 | 66672 | 68880 | 62867 | 59794 | 56724 |
| Total Equity | **122249** | **125264** | **121729** | **120515** | **119289** | **118051** | **116800** | **107329** | **100797** | **94268** |
| Total Liabilities and Equity | **159944** | **153235** | **144292** | **137671** | **131038** | **124393** | **117737** | **108289** | **101780** | **95274** |

Draft

| Calendar Year | 2031<br>21 | 2032<br>22 | 2033<br>23 | 2034<br>24 | 2035<br>25 | 2036<br>26 | 2037<br>27 | 2038<br>28 | 2039<br>29 | 2040<br>30 |
|---|---|---|---|---|---|---|---|---|---|---|
| Assets | | | | | | | | | | |
| <u>Current Assets</u> | | | | | | | | | | |
| Cash | 14364 | 14364 | 14364 | 14364 | 14364 | 14364 | 14364 | 14364 | 14364 | 14364 |
| Accounts receivable | 6477 | 6633 | 6792 | 6955 | 7122 | 7293 | 7468 | 7647 | 7831 | 8019 |
| Total Current Assets | **20841** | **20997** | **21156** | **21319** | **21486** | **21657** | **21832** | **22011** | **22195** | **22383** |
| Fixed Assets | | | | | | | | | | |
| Opening Book Value | 74584 | 74584 | 74584 | 74584 | 74584 | 74584 | 74584 | 74584 | 74584 | 74584 |
| Depreciation | | | | | | | | | | |
| Net Fixed Assets | 74584 | 74584 | 74584 | 74584 | 74584 | 74584 | 74584 | 74584 | 74584 | 74584 |
| Total Assets | **95425** | **95581** | **95740** | **95903** | **96070** | **96241** | **96416** | **96595** | **96779** | **96967** |
| Liabilities | | | | | | | | | | |
| <u>Current Liabilities</u> | | | | | | | | | | |
| Bank Overdraft | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Accounts payable | 1030 | 1055 | 1080 | 1106 | 1133 | 1160 | 1188 | 1216 | 1246 | 1275 |
| Total current liabilities | **1030** | **1055** | **1080** | **1106** | **1133** | **1160** | **1188** | **1216** | **1246** | **1275** |
| <u>Long term Liabilities</u> | | | | | | | | | | |
| Deferred Income Tax | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Long term loan | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Current maturity | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Total long term loans | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Total Long term Liabilities | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **Total Liabilities** | **1030** | **1055** | **1080** | **1106** | **1133** | **1160** | **1188** | **1216** | **1246** | **1275** |
| Equity | | | | | | | | | | |
| <u>Share Capital</u> | | | | | | | | | | |
| Preferred Shares | | | | | | | | | | |
| Common Shares | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 |
| Total Shares Capital | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 | 37544 |
| Retained Earnings | 56852 | 56982 | 57116 | 57253 | 57394 | 57537 | 57685 | 57835 | 57990 | 54148 |
| **Total Equity** | **94396** | **94526** | **94660** | **94797** | **94938** | **95081** | **95229** | **95379** | **95534** | **91692** |
| Total Liabilities and Equity | **95426** | **95581** | **95740** | **95903** | **96071** | **96241** | **96417** | **96595** | **96780** | **92967** |

**<u>បញ្ជាក់៖</u>** មានលម្អិតនៅក្នុងឧបសម្ព័ន្ធ៧

Draft

# ជំពូក ១១

## សន្និដ្ឋាន និង អនុសាសន៍

## Conclusions and Recommendations

Draft

# ជំពូកទី ១១

# សន្និដ្ឋាន និង អនុសាសន៍

## ១១.១ សន្និដ្ឋាន

ការវាយតំលៃបរិស្ថាន និងសង្គមលើគំរោងវិនិយោគសំរាប់អភិវឌ្ឍន៍វារីអគ្គិសនីកំចាយខេត្តកំពត របស់ក្រុមហ៊ុន Kamchay Sinohydro Hydroelectric Co,Ltd. ដែលក្រុមហ៊ុនបានឱ្យ SAWAC Consultants for Development ធ្វើការសិក្សាស្រាវជ្រាវដើម្បីរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានសង្គមនេះអាចធ្វើសេក្តីសន្និដ្ឋានដូចតទៅ :

គំរោងវិនិយោគនេះ មានទឹកប្រាក់ចំនួន ២៨០លាន ដុល្លារសហរដ្ឋអាមេរិក ដែលអាចផលិតថាមពលអគ្គិសនី បានចំនួន ១៩៤.១មេហ្គាវ៉ាត់ ។ គំរោងនេះ រដ្ឋាភិបាលបានធ្វើកិច្ចសន្យាសម្បទានឱ្យក្រុមហ៊ុនដំណើរការផលិតថាមពលអគ្គិសនី និងលក់ថាមពលអគ្គិសនីជូនរដ្ឋរយៈពេល៤០ឆ្នាំ និងការសាងសង់រយៈពេល៤ឆ្នាំ ដែលបានចាប់ផ្តើមសាងសង់នៅ ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០០៧ ដែលនឹងបញ្ចប់នៅខែវិច្ឆិកា ឆ្នាំ២០១១ ។

ជាទូទៅគំរោងវារីអគ្គិសនី នឹងធ្វើឱ្យមានការប៉ះពាល់ខ្លាំងលើបរិស្ថានរូបសាស្ត្រ គឺក្នុងដំណាក់កាលសាងសង់គំរោង និងដំណាក់កាលក្រោយសាងសង់គំរោងតាមការសិក្សាគំរោងវារីអគ្គិសនីកំចាយបានឱ្យដឹងថាការប៉ះពាល់លើបរិសាស្ត្ររូបសាស្ត្រ នឹងធ្វើឱ្យប៉ះពាល់តំបន់កំសាន្តទឹកឈូរ និងប៉ះពាល់ដល់ជីវសាស្ត្រសត្វព្រៃ និងមច្ឆជាតិ ។

ការសាងសង់ទំនប់នឹងធ្វើឱ្យប៉ះពាល់ដល់ការធ្វើចរាចរត្រីសំខាន់ៗ ចំនួន ១៥ប្រភេទ ។

ផលប៉ះពាល់អវិជ្ជមាន លើតំលៃបរិស្ថាន ក្នុងការវិនិយោគគំរោងវារីអគ្គិសនីកំចាយ

**តារាងលេខ ៨៧ : សន្និដ្ឋាន ផលប៉ះពាល់អវិជ្ជមានលើតំលៃបរិស្ថាន ក្នុងការវិនិយោគគំរោងវារីអគ្គិសនីកំចាយ**

| | | | | |
|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| | [redacted] | [redacted] | [redacted] | |
| | [redacted] | [redacted] | | |

**សំគាល់:** *ចំណុចទី៤ក្រុមហ៊ុនបានទូទាត់សំណងរួចរាល់ហើយ*

សត្វព្រៃសំខាន់ៗ រួមមានថនិកសត្វ ចំនួន ៣៧ប្រភេទ បក្សីចំនួន ៦៨ ប្រភេទល្មូនចំនួន ២៣ប្រភេទ ដែលធ្លាប់រស់នៅក្នុង តំបន់គំរោង ត្រូវបាត់បង់ជំរក និងទៅរកកន្លែងជំរកថ្មី ។

Draft

ប្រភេទត្រីសំខាន់ៗ ដែលអ្នកនេសាទចាប់បានចំនួន១៥ប្រភេទ ក្នុងតំបន់គំរោងមានការប៉ះពាល់ខ្លាំង ក្នុងដំណាក់កាលសាងសង់គំរោង ទ្រង់ទ្រាយធំ ឆ្នាំ២០១០ គឺបរិមាណផលចាប់ត្រីទាំងនេះ នៅផ្នែកខាងក្រោមតំបន់គំរោងនៅពេល ទឹកជំនន់ មានការថយចុះ ៩៥ភាគរយ ធៀបឆ្នាំ ២០០៦ ។

នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៦ (កិច្ចសន្យាមានចែងក្នុងឧបសម្ព័ន្ធ ១) ។ គំរោងនេះនឹង ធ្វើឱ្យបាត់បង់ ទាំងស្រុងនូវព្រៃស្រោង ដែលមានផ្ទៃដី ១៤១៧,៥៦ ហិកតា និងព្រៃល្បាយឬស្សី ដែលមានផ្ទៃដី ១៣៩,៧៤ ហិកតា (ពិពណ៌នាលំអិតនៅក្នុងជំពូក ៤ កថាខ័ណ្ឌ ៤.២.៤ ផែនទីលេខ ៣ និងជំពូក ៥ កថាខ័ណ្ឌ ៥.៣.២.២) ។ គំរោងនេះអាចមានការប៉ះពាល់ដល់សត្វព្រៃ និងជំរករបស់វា (មានចែងក្នុងជំពូក ៥ កថាខ័ណ្ឌ ៥.២.៥) ក៏ប៉ុន្តែ ក្រុមហ៊ុននឹងបង្កលក្ខណៈ ងាយស្រួលសំរាប់ការបំលាស់ទីរបស់ជីវៈចំរុះទាំងនោះ ទៅកន្លែងព្រៃឧទ្យានជាតិ បូកគោ ដែលនៅជាប់ គ្នានេះ ។

អាចនឹងប៉ះពាល់ដល់ការប្រើប្រាស់កាន់កាប់ដីរបស់ប្រជាពលរដ្ឋក្នុងតំបន់ទឹកឈូប្រមាណ ១១០ហ.ត រួមមាន ដី ចំការចំនួន ១៩ម្ចាស់ នៅផ្នែកខាងស្តាំស្ទឹង និងមានដីចំការចំនួន ១៣ម្ចាស់ នៅផ្នែកខាងឆ្វេងស្ទឹង ដោយសាររចនាសម្ព័ន្ធតំបន់ ទំនប់ទីពីរ (រាប់ចាប់ពីទំនប់ទីពីររហូតដល់ស្ពានដែក) ។ ជាងនេះទៀតមានកម្មករចំនួន ៣៨គ្រួសារ ដែលកំពុងធ្វើចំការ និងរស់នៅលើដីទាំងនោះ ហើយដែលនឹងប្រឈមនឹងការបាត់បង់ការងារ និងជំរករស់នៅរបស់គាត់ ។

គំរោងក៏នឹងមានបញ្ហាចំពោះសិទ្ធប្រើប្រាស់ទឹក ជាមួយអ្នកប្រើប្រាស់ទឹកក្នុងព្រែកទឹកឈូទាំងអស់ ជាពិសេសអាច មានបញ្ហាចោទខ្លាំងបង្គួរ ជាមួយរដ្ឋាករទឹកក្រុងកំពត លើភាពមិនប្រក្រតីនៃបរិមាណ និងគុណភាពប្រភពទឹក ។

ប្រភពទឹកលើដី (អូរ ព្រែក) ក្នុងតំបន់គំរោងខ្សែទឹកខាងលើ មិនទាន់មានការបំពុលពីសកម្មភាពរបស់មនុស្សទេ ។ ទោះបីជាមានប៉ារ៉ាម៉ែត្រ មួយចំនួនលើសពី ស្តង់ដាគុណភាពទឹករបស់ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល និង ស្តង់ដាគុណភាពទឹកក្នុងប្រភព ទឹកសាធារណៈ សំរាប់រក្សាជីវសាស្ត្រចំរុះ របស់ក្រសួងបរិស្ថានក៏ដោយ ព្រោះវា កើតចេញពីធម្មជាតិ ក្នុងតំបន់គំរោងនេះតែប៉ុណ្ណោះ ។ តែនៅខ្សែទឹក ខាងក្រោមចាប់ពីកន្លែងកំសាន្តទឹកឈូ ចុះមកក្រោម ឃើញមានសញ្ញានៃសកម្មភាពបំពុលពីមនុស្ស សំណល់រាវរឹងពីទីក្រុង និងទឹក ប្រៃជោរចូលមក ។

គំរោងនេះពុំមានហេតុប៉ះពាល់ធ្ងន់ធ្ងរទៅលើបរិស្ថាន និងសង្គមទេ ពីព្រោះក្រុមហ៊ុនបានរៀបចំវិធានការកាត់បន្ថយនូវការប៉ះពាល់អវិជ្ជមាន ឱ្យដល់កំរិតអប្បបរមា ទៅតាមដែលក្រុមហ៊ុនមានបទពិសោធន៍ជាច្រើនឆ្នាំនៅប្រទេសចិន និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនទៀត ។ ជាឧទាហរណ៍ សង្ខេបពីវិធានការការពារ និងកាត់បន្ថយសំរាប់សំណល់ ដែលមានសារ-ធាតុ ប្រេង និងសារធាតុគីមី ឬសំណល់រឹងផ្សេងៗទៀត ក្រុមហ៊ុននិងទុក ដាក់គ្រប់គ្រងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។ បន្ថែមពីលើនេះក្រុមហ៊ុននឹងបំពាក់ឧបករណ៍សំអាតទឹកកខ្វក់ ដែលមានសមត្ថភាពគ្រប់គ្រាន់ យោងតាមការបញ្ចេញចោលរបស់គំរោងនេះ ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុននឹងសហការជាមួយ ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធ ក្នុងការត្រួតពិនិត្យ និងផ្តល់យោបល់លើសកម្មភាពនៃការគ្រប់គ្រងសំណល់រឹង និងរាវជាប្រចាំ ។ ប៉ុន្តែគំរោងវារីអគ្គិសនីកំចាយនេះអាចនឹងមាន ហានិភ័យកំរិតខ្ពស់ ដូចជាការបាក់ភ្នំ ការបាក់ទំនប់ជាដើម ក្នុងពេលសាងសង់ និងពេលដំណើរការ ដូចមានរ៉ាយរ៉ាប់លម្អិតក្នុង ជំពូក៥ នៃរបាយការណ៍នេះ ។

ទន្ទឹមនឹងផលប៉ះពាល់អវិជ្ជមានដល់ធនធានធម្មជាតិ និងបរិស្ថានសង្គមមួយចំនួន គំរោងក៏នឹងផល់ផលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ដល់ប្រជាជនមូលដ្ឋាន និងសង្គមជាតិទាំងមូលផងដែរ ដូចជា ៖

ប្រទេសកម្ពុជានឹងមានទំនប់វារីអគ្គិសនីធំជាងគេ (១៩៤.១MW) លើកដំបូងនៅក្នុងប្រវត្តិសាស្ត្រសង្គមជាតិ ដែលសមត្ថភាពរបស់វាអាចផលិតថាមពលអគ្គិសនីបាន ៤៨៨ ជីហ្កាវ៉ាត់ម៉ោង (GWh) គឺប្រមាណជា ៦៧% នៃ ថាមពលអគ្គិសនីដែល ប្រទេសកម្ពុជាផលិតបានសរុបនៅឆ្នាំ២០០៤ ហើយគំរោងវារីអគ្គិសនីកំចាយនឹងផ្តល់ថាមពលអគ្គិសនី យ៉ាងចំបងអាចឆ្លើយតបដ៏មានប្រសិទ្ធភាព ចំពោះដំណោះស្រាយប្រភពអគ្គិសនីសំរាប់ប្រទេសកម្ពុជាក្នុងរយៈពេលមធ្យម ។ នៅពេលគំរោងនេះដំណើរការ ប្រទេសកម្ពុជានឹងមានថាមពលអគ្គិសនីទ្វេរដងនៃកំលាំងថាមពលអគ្គិសនីផលិតសរុបក្នុងឆ្នាំ ២០០៥ ។ ជាងនេះទៀតគំរោងវារីអគ្គិសនីកំចាយ នឹងផ្តល់ស្ថេរភាពក្នុងការផ្គត់ផ្គង់ភ្លើងអគ្គិសនីដល់ អ្នកប្រើប្រាស់ តាម រោងចក្រឧស្សាហកម្មនានា លំនៅដ្ឋាន ទីសាធារណៈ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិកម្ពុជា ដើម្បីរំដោះភាពក្រីក្រ របស់ប្រជាជនក្នុងតំបន់គំរោង និងទូទាំងប្រទេសព្រមទាំងធ្វើឱ្យសង្គមជាតិរីកចំរើនលើគ្រប់វិស័យ ។

តាមរយៈគំរោងនេះនឹងផ្តល់ការងារដល់ប្រជាពលរដ្ឋកម្ពុជាប្រមាណ ២២៣៦នាក់ ក្នុងតំណាក់កាលសាងសង់ និងមួយចំនួនតូចទៀតនៅពេលប្រតិបត្តិការ និងថែទាំ ។ គំរោងនឹងបង្កើតប្រាក់ចំណូលដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានតាមរយៈចូលបំរើការ ជាបុគ្គលិក កម្មករ ទាំងពេលសាងសង់ និងពេលប្រតិបត្តិការថែទាំ ។ ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចបង្កើនចំណូលដល់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានតាមរយៈទេសចរជាតិ និងអន្តរជាតិ មកតំបន់ទឹកឈូ និងការទស្សនាទំនប់វារីអគ្គិសនីកំចាយនេះទៀតផង ។

គំរោងវារីអគ្គិសនីកំចាយ អាចជួយបន្ថយជំនន់ធំៗក្នុងតំបន់ភ្នំកំចាយនេះបានមួយផ្នែក ។ បើជំនន់ដើមរដូវវស្សាអាចទប់បានមួយផ្នែកធំ តែបើជំនន់ចុងរដូវវស្សា នោះអាចទប់បានមួយផ្នែកតូចប៉ុណ្ណោះ ។ បើគំរោងមានការប្រលែងបញ្ចេញទឹកពីទំនប់ទីពីរមិនតិចជា ០,៣ម៣/វិនាទី ទ្បេងទាត់ឥតដាច់ នៅរដូវប្រាំងនោះធ្វើឱ្យព្រែកកំចាយមានលំនឹងបរិស្ថានល្អប្រសើរ និងទប់ស្កាត់ការជ្រាបចូលជ្រៅនៃទឹកប្រៃពីសមុទ្រមកតំបន់ទឹកឈូ ដែលផ្តល់ប្រយោជន៍យ៉ាងច្រើនដល់ការប្រើប្រាស់ទឹកសាបសំរាប់ស្រោចស្រពដំណាំ ការកំសាន្ត និងជាពិសេសការផ្គត់ផ្គង់ទឹកស្អាត របស់រដ្ឋាករទឹកក្រុងកំពត ។

ក្រុមហ៊ុននឹងពង្រីកតំបន់ទេសចរណ៍ នៅក្នុង និងជុំវិញតំបន់គំរោង និងជួយដល់ហេដ្ឋារចនាសម្ព័ន្ធសង្គម ផ្សេងទៀត។

គំរោងស្តារបរិស្ថានឡើងវិញចំនួន ១២.០០០.០០០ ដុល្លារអាមេរិក សំរាប់ដំណាក់កាលសាងសង់ រយៈពេល៤ឆ្នាំ និង៥.៥០០.០០០ ដុល្លារអាមេរិក សំរាប់ ដំណាក់កាលក្រោយសាងសង់ រយៈពេល ៤០ឆ្នាំ ។

ក្រៅពីនេះ ក្រុមហ៊ុននឹងសាងសង់ទំនប់នៅផ្នែកខាងក្រោមទំនប់ទីពីរ ដើម្បីអភិរក្សត្រីពូជ ដែលមានប្រភពពីតំបន់គំរោង និងតំបន់ជុំវិញគំរោង ។ ផ្តល់ត្រីមេពូជក្នុងស្រុក ប្រលែងចូលក្នុងតំបន់អភិរក្ស និងជុំវិញតំបន់គំរោង រយៈពេល១០ឆ្នាំ ចំនួន ១០០.០០០ក្បាល ក្នុង ១ ឆ្នាំ គិតជាតំលៃ ០.៧៥ ដុល្លារ/ក្បាល គឺស្មើនឹង ៧.៥០០ ដុល្លារ/ឆ្នាំ សរុប១០ឆ្នាំ ស្មើនឹង ៧៥.០០០ ដុល្លារ ។

គំរោងនេះនឹងមានសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងតំបន់នេះ ដូចជា កែលំអផ្លូវចេញចូលតំបន់ទឹកឈូ ឱ្យមានលក្ខណៈល្អប្រសើរ សាងសង់ផ្លូវនិងស្ពានចេញចូលពីការដ្ឋានយកថ្ម ផ្លូវជុំវិញអាង ស្តុកទឹកទាំងពីរ ។ល។ ក្រៅពីហេដ្ឋារចនាសម្ព័ន្ធបំរើឱ្យសាធារណជន គំរោងមានសាងសង់អគារស្នាក់នៅឱ្យបុគ្គលិកកម្មករ ការិយាល័យ សួនច្បារ និងអាងលេងទឹកសំរាប់ការប្រើប្រាស់របស់បុគ្គលិកគំរោង និងធ្វើឱ្យមានសោភណ្ឌភាពដល់ តំបន់គំរោងទាំងមូលទៀតផង ។



Draft

ដោយសារឥទ្ធិពលនៃការអភិវឌ្ឍគំរោង និងហេដ្ឋារចនាសម្ព័ន្ធរបស់វា អាចនឹងធ្វើឱ្យដីក្នុងតំបន់កើនតំលៃខ្ពស់ជាងបច្ចុប្បន្ននេះ (២០០៦) ជាពិសេសការប្រើប្រាស់ដីសំរាប់វិស័យឧស្សាហកម្ម កសិកម្មទំនើប និងទេសចរណ៍ ។ ដោយសារហេដ្ឋារចនាសម្ព័ន្ធរបស់គំរោង អាចទាក់ទាញអ្នកទេសចរជាតិ និងអន្តរជាតិមកទស្សនានៅក្នុងតំបន់គំរោង តំបន់ទឹកឈូ តំបន់បូកគោ និងតំបន់ក្បែរខាង ទៅថ្ងៃអនាគតយ៉ាងសន្ធឹកសន្ធាប់ទៀតផង ហើយនឹងធ្វើឱ្យខេត្តកំពតទាំងមូលក្លាយជាប៉ូលទេសចរណ៍យ៉ាងសំខាន់មួយ សំរាប់ប្រទេសកម្ពុជាយើងផងដែរ ។

គំរោងមានការបង់ផ្ទាល់ចូលចំណូលថវិការជាតិ ដោយសារក្រុមហ៊ុននឹងត្រូវបង់ពន្ធអាករ លើការនាំចូល ប្រេងឥន្ធនៈសំរាប់ប្រើប្រាស់ក្នុងការសាងសង់ ពន្ធកាត់ទុក ពន្ធលើប្រាក់ចំណេញ និងពន្ធអាករផ្សេងៗទៀត ក្នុងរយៈពេលប្រតិបត្តិការ និងថែទាំគំរោង ទៅតាមកិច្ចសន្យារវាងក្រុមហ៊ុន ជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

## ១១.២ អនុសាសន៍

ដើម្បីទទួលបានភាពរលូនក្នុងការអនុវឌ្ឍនគំរោងវារីអគ្គិសនីកំចាយ និងពង្រឹងភាពទទួលខុសត្រូវចំពោះកិច្ចអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តភាពលើធនធានធម្មជាតិ និងសុវត្ថិភាពសង្គម នោះតាមរយៈការសិក្សាវាយតំលៃផលប៉ះពាល់បរិស្ថាន និងសង្គមសំរាប់គំរោងវារីអគ្គិសនីនេះ SAWAC សូមផ្តល់អនុសាសន៍សំខាន់ៗមួយចំនួនដូចតទៅ -:

- ក្រុមហ៊ុនត្រូវសិក្សារចនាប្លង់នៃសមាសភាពគំរោងទាំងអស់ ដែលធានាដល់ភាពល្អប្រសើរតាមលក្ខណៈបច្ចេកទេស និង កាត់បន្ថយផលប៉ះពាល់ដីធ្លី លំនៅដ្ឋាន និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង ។
- រដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងពាក់ព័ន្ធ ត្រូវដោះស្រាយបញ្ហាការបាត់បង់ដីធ្លី លំនៅដ្ឋាន ទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាពលរដ្ឋ និងមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ពួកគេ ទៅតាមផ្លូវច្បាប់ និងតាមស្ថានភាពជាក់ស្តែង ដោយមិនបំពារបំពានលើប្រជាពលរដ្ឋដែលរងគ្រោះដោយសារសកម្មភាពគំរោងវារីអគ្គិសនីកំចាយនេះ ។
- ក្រុមហ៊ុនត្រូវធ្វើសហប្រតិបត្តការយ៉ាងពេញទំហឹង (ទាំងថវិកា និងបច្ចេកទេស) ជាមួយឧទ្យានជាតិបូកគោ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីដាំព្រៃឈើឡើងវិញក្នុងតំបន់ក្បែរខាងគំរោងគឺរួមចំណែកស្តារឡើងវិញនូវការបាត់បង់ព្រៃឈើ និងជាជំរកសត្វព្រៃ ហើយធ្វើឱ្យមានលំនឹងបរិស្ថាននៃឧទ្យានជាតិ បូកគោទៀតផង ។
- ក្រុមហ៊ុនត្រូវធ្វើកិច្ចពិភាក្សាជាមួយរដ្ឋាករទឹក និងមន្ទីរឧស្សាហកម្មខេត្តកំពត ព្រមទាំងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីផ្លាស់ប្តូរទីតាំងស្ថានីយ៍បូមទឹក (Intake Station) ទៅនៅក្នុងតំបន់អាងទីពីរ ដែលជាមធ្យោបាយប្រសើរបំផុតសំរាប់ ដោះស្រាយបញ្ហាគុណភាពទឹក និងកង្វះទឹក ។
- គំរោងគួរតែរចនាប្លង់ឱ្យមានការបញ្ចេញទឹកពីទំនប់ទីពីរមកខ្សែទឹកខាងក្រោម ដោយធានានូវបរិមាណធារទឹកយ៉ាងតិចបំផុត ៦ម$^{៣}$/វិនាទី យ៉ាងទៀងទាត់ឥតដាច់នៅរដូវប្រាំង ដើម្បីធ្វើឱ្យព្រែកនេះមានលំនឹង បរិស្ថានកាន់តែប្រសើរ និងបញ្ចៀសបាននូវការហូរចូលមកនូវទឹកប្រៃក្នុងតំបន់ទឹកឈូនោះ ។



Draft

- ក្រុមហ៊ុនត្រូវមានការប្រុងប្រយ័ត្ន និងត្រៀមគ្រប់គ្រងហានិភ័យឱ្យបានកំរិតខ្ពស់ ដូចជា ការសិក្សា ភូគព្ភសាស្ត្រ និងបរិស្ថានក្នុងតំបន់គំរោងឱ្យបានហ្មត់ចត់ ការរចនាប្លង់ គុណភាពសំណង់ធានាបានមិនឱ្យ មានការបាក់ទំនប់ បាក់ភ្នំ ។ ត្រៀមគ្រប់គ្រងហេតុការដែលអាចកើតឡើងផ្សេងៗ ដោយប្រព័ន្ធផ្សព្វផ្សាយគ្រប់គ្រាន់ និងទាន់ពេលវេលាអ្នកជួយសង្គ្រោះ និងសំភារះសង្គ្រោះ ព្រមទាំងថវិកាសំរាប់ដោះស្រាយ ជាបន្ទាន់ទៀតផង ។

ជាទីបញ្ចប់នេះ ក្រុមហ៊ុន Kamchay Sinohydro Hydroelectric Co,Ltd. ដែលជាម្ចាស់គំរោងវិនិយោគសំរាប់អភិវឌ្ឍន៍វារី អគ្គិសនីកំចាយ ខេត្តកំពត គឺមានឱកាសផ្តល់នូវផលប្រយោជន៍ជាច្រើនដល់រាជរដ្ឋាភិបាល និងជាពិសេស ដល់ប្រជា-ពលរដ្ឋ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍របស់ប្រទេសជាតិ ។ ដូចនេះក្រុមហ៊ុនមានសំណូមពរដល់ ក្រសួងបរិស្ថាន និងក្រសួងពាក់ព័ន្ធមួយចំនួនទៀត ព្រមទាំងរាជរដ្ឋាភិបាលកម្ពុជា មេត្តាជួយបង្កលក្ខណៈងាយស្រួល និងចេញ លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនស្របតាមច្បាប់វិនិយោគ និងច្បាប់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិបានទាន់ ពេលវេលាដែលបានគ្រោងទុកយ៉ាងពិតប្រាកដ ។

រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ.............ឆ្នាំ ២០១១

**នាយកក្រុមហ៊ុន** SINOHYDRO Corporation Limited

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែមេសា ឆ្នាំ ២០១១

**នាយក** SAWAC Consultants for Development

Draft